# ប្រវត្តិព្រះបរមសារីរិកធាតុសង្ខេប

រៀបរៀងដោយ

**ធម្មានន្ទ  វ៉ាន់  ចាន់សារ៉ែន**

ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

ព.ស.២៥៥៣

ឆ្នាំ ២០១០

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# ធម្មានន្ទ វ៉ាន់ ចាន់សារ៉ែន និងសហការីទទួលព្រះបរមសារីរិកធាតុ
# នៃព្រះសម្មាសម្ពុទ្ធជាអម្ចាស់



# ប្រវត្តិព្រះបរមសារីរិកធាតុ

ព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចទាំង ៥ ប្រការ អស់ ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោកតែម្យ៉ាង មិនមានបំណងប៉ងប្រាថ្នាអ្វីបន្តិចបន្តួចពីសត្វលោកឡើយ ។ ព្រះអង្គទ្រង់បំពេញពុទ្ធចរិយា មិនគិតពីការនឿយហត់លំបាកកាយឡើយ ឲ្យតែសត្វលោកបានរួចផុតចាកទុក្ខ បានត្រាស់ដឹងនូវអរិយសច្ចធម៌ ។ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ចអស់ ៤៥ ឆ្នាំហើយ ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ ពិសាខ មុនពុទ្ធសករាជ ១ ថ្ងៃ ព្រះអង្គទ្រង់បរិនិព្វានក្រោមសាលព្រឹក្សទាំងគូ ដោយអនុបាទិសេស-និព្វាន ។ ព្រះបរមសពនៃព្រះអរហន្តសម្មាសម្ពុទ្ធ ត្រូវពួកមនុស្សទេវតាព្រហ្មជាដើមនាំគ្នាបូជាយ៉ាងសន្ធឹកសន្ធាប់ជាទីបំផុត ហើយបានដង្ហែយកទៅបូជាត្រង់មកុដពន្ធនចេតិយ ។

ក្នុងថ្ងៃទី ៧ បន្ទាប់ពីព្រះអង្គទ្រង់បរិនិព្វាន ព្រះបរមសព ដែលតម្កល់លើចិតកាធានត្រូវភ្លើងឆេះឡើង ដោយអំណាចនៃទេវតាបណ្ដាលឡើង ព្រះបរមសពនៃព្រះដ៏មានព្រះភាគអស់រូបរាងកាយ ធារទឹកបានធ្លាក់ហូរចុះពីលើអាកាសបានពន្លត់ចិតកាធានរបស់ព្រះសាស្ដា នៅសល់តែព្រះបរមធាតុនៃព្រះដ៏មានព្រះភាគប៉ុណ្ណោះ ។ ពួកមល្លក្សត្របានអារាធនាព្រះបរមសារីរិកធាតុទាំងអស់ ទៅដាក់ទុកក្នុងសុវណ្ណទោណ ប្រោះព្រំដោយទឹកក្រអូបគ្រប់ប្រភេទ រោយរាយគន្ធជាតិក្នុងសុវណ្ណទោណ ហើយបាននាំសុវណ្ណទោណទៅប្រតិស្ឋានលើដីរីដែលប្រដាប់តាក់តែងហើយ និងទ្រង់

បូជាដោយវត្ថុទាំងឡាយមានកម្រងផ្កានិងគ្រឿងក្រអូបជាដើម ហើយក៏នាំយកព្រះបរមសារីរិកធាតុចូលទៅកាន់ក្នុងនគរ តម្កល់ទុកលើសត្តរតនមយ-បល្ល័ង្កគឺបល្ល័ង្កដែលធ្វើដោយរតនៈ ៧ ប្រការ ក្នុងសណ្ឋាគារបាំងស្វេតច្ឆត្រពីខាងលើ ហើយនាំគ្នារៀបចំធ្វើសក្ការបូជាចំពោះព្រះបរមសារីរិកធាតុនៃព្រះដ៏មានព្រះភាគ រហូតអស់ ៧ ថ្ងៃទៀត ។

## ការចែកព្រះបរមសារីរិកធាតុ

ក្នុងកាលណោះព្រះរាជាក្នុងដែនផ្សេងៗ មានព្រះបាទមាគធអជាសត្តុជាដើមទ្រង់បានឮដំណឹងថា ព្រះដ៏មានព្រះមានព្រះភាគទ្រង់បរិនិព្វានហើយក្នុងក្រុងកុសិនារា ហើយបញ្ជូនរាជទូតទៅកាន់សំណាក់នៃពួកមល្លក្សត្រអ្នកក្រុងកុសិនារាថា ព្រះដ៏មានព្រះភាគជាក្សត្រយើងក៏ជាក្សត្រ យើងគួរបានចំណែកនៃព្រះសារីរិកធាតុរបស់ព្រះដ៏មានព្រះភាគដែរ យើង ធ្វើស្តូបផង ការបូជាផងចំពោះព្រះសារីរិកធាតុនៃព្រះដ៏មានព្រះភាគ ។ តែ ពួកមល្លក្សត្រគិតថា ធម្មតាពុទ្ធរតនៈជាវត្ថុដ៏ប្រសើរបំផុតក្នុងលោក ព្រមទាំងទេវលោក ក៏រតនៈនេះកើតក្នុងគាមក្ខេត្តរបស់យើង យើងមិនព្រមឲ្យដល់អ្នកណាទេ ។ កាលបើពួកមល្លក្សត្រមិនព្រមចែកព្រះសារីរិកធាតុយ៉ាងនេះ ។ ព្រះរាជា និងព្រាហ្មណ៍ទាំងអស់នោះ ចាប់ផ្តើមនាំគ្នាធ្វើចម្បាំងដើម្បីដណ្តើមយកព្រះសារីរិកធាតុ ។ ក៏រៀបចំកងទ័ពរៀងៗខ្លួនដើម្បីឡោមពទ្ធក្រុងកុសិនារា ។ ឯពួកមល្លក្សត្រអ្នកក្រុងកុសិនារាវិញ ក៏បានរៀបចំកងទ័ពតតាំងច្បាំងវិញដែរ ។ ក្នុងកាលណោះទោណព្រាហ្មណ៍គាត់

ជាអាចារ្យរបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះ ឃើញការវិវាទទាស់ទែងគ្នា ដោយសារព្រះសារីរិកធាតុជារឿងមិនសមគួរទាល់តែសោះ ទើបឡើងទៅឈរលើកំពែងទីខ្ពស់ស្រែកឡើងថា ៖

លោកទាំងឡាយដ៏ចំរើន សូមស្តាប់ពាក្យខ្ញុំមួយម៉ាត់សិន ព្រះពុទ្ធជាម្ចាស់នៃយើង ព្រះអង្គជាខន្តិវាទ (អ្នកពោលសរសើរនូវខន្តីមែនពិត) ការប្រហារគ្នា ច្បាំងគ្នា ព្រោះចំណែកនៃព្រះសារីរិកធាតុរបស់ឧត្តមបុរសនេះ មិនប្រពៃឡើយ ។ បពិត្រលោកដ៏ចំរើនទាំងឡាយ យើងទាំងអស់គ្នា គួរតែស្រុះស្រួលគ្នា ព្រមព្រៀងគ្នា រីករាយរកគ្នា ចែកព្រះសារីរិកធាតុឲ្យជា៨ចំណែក ព្រះស្តូបទាំងឡាយ សូមផ្សាយទៅក្នុងទិសទាំងឡាយចុះ ពួកជនច្រើនជ្រះថ្លាចំពោះព្រះសម្ពុទ្ធមានចក្ខុមិនលែង ។

កាលទោណព្រាហ្មណ៍ពោលពាក្យនេះលើកទី ១ គ្មានអ្នកណាយកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះម្នាក់ៗគិតតែថា ត្រូវច្បាំងៗ ។ តែអាស្រ័យទោណព្រាហ្មណ៍គាត់ជាអាចារ្យរបស់ក្សត្រ និងព្រាហ្មណ៍ទូទាំងជម្ពូទ្វីប មិនមានក្សត្រនិងព្រាហ្មណ៍ណាមួយថា មិនស្គាល់ឡើយ ។

ពេលនោះទោណព្រាហ្មណ៍ស្រែកប្រកាសយ៉ាងខ្លាំងជាលើកទីពីរថា

ពួកលោកចាំសំឡេងអាចារ្យរបស់ខ្លួនមិនបានទេឬ ? ប្រសិនបើចាំបាន សូមស្ងាត់ស្ងៀមគ្រប់ ៗ គ្នា ហើយស្ដាប់វាចាដែលខ្ញុំពោល ។ ពួកក្សត្រទាំងនោះ បានឮសំឡេងស្រែកឡើងនោះ ក៏ចាំបានថា នេះជាសំឡេងរបស់ទោណព្រាហ្មណ៍ ជាអាចារ្យរបស់ខ្លួន ហើយក៏នាំគ្នាស្ងៀមស្ងាត់ទៅ ។ ទោណព្រាហ្មណ៍ក៏ប្រកាសឡើង ដូចពាក្យមុននោះឯងដើម្បីបបួលគ្នាចែកព្រះបរមសារីរិកធាតុឲ្យជា ៨ ចំណែកសម្រាប់ក្សត្រនិង ព្រាហ្មណ៍ ៨ នគរ ដែលមកជួបជុំគ្នាក្នុងពេលនោះ ។ ក្សត្រនិងព្រាហ្មណ៍ព្រមតាមទោណព្រាហ្មណ៍ មានឆន្ទៈតែមួយថា នឹងចែកឲ្យបានស្មើៗគ្នា ។ ទោណព្រាហ្មណ៍បានដឹងពីការព្រមព្រៀងគ្នារបស់ក្សត្រ និងព្រាហ្មណ៍ទាំងនោះហើយ ក៏បានបញ្ជាឲ្យគេបើកតុម្ពមាសឡើង ដើម្បីចែកព្រះបរមសារីរិកធាតុ ។ ពេលនោះ ព្រះរាជាទាំងឡាយបានឈរនៅជិតឯតុម្ពមាសនោះ ឃើញព្រះធាតុមានពណ៌ដូចជាមាស ក៏ខ្សឹកខ្សួលកន្ទក់កន្ទេញថា ព្រះដ៏មានព្រះភាគជាសព្វញ្ញូ ក្នុងកាលមុន យើងបានឃើញសរីរៈរបស់ព្រះអង្គមានពណ៌ដូចមាស ដែលប្រដាប់តាក់តែងហើយដោយបុរិសលក្ខណៈ ៣២ ប្រការ ដែលមានឆព្វណ្ណរង្សី ៦ ប្រការ និងលម្អរុងរឿងទៅដោយអនុព្យញ្ជនៈ ៨០ ឥឡូវនេះនៅសល់តែព្រះធាតុមានពណ៌ដូចមាសប៉ុណ្ណោះ ។ ឯទោណព្រាហ្មណ៍ដឹងនូវសេចក្ដីធ្វេសប្រហែសរបស់ក្សត្រនិងព្រាហ្មណ៍ទាំងនោះ ក៏ចាប់យកទក្ខិណទាឋៈ គឺចង្កូមកែវខាងស្ដាំ ដាក់ក្នុងចន្លោះឈ្នួតក្បាល ។ កាលបើក្សត្រនិងព្រាហ្មណ៍ទាំងនោះ

បន្ទាប់សេចក្ដីសោកខ្សឹកខ្សួលហើយ ក៏បាននាំគ្នាចែកព្រះធាតុនោះ ៨ ចំណែកគឺ ៖

១.ព្រះបាទមាគធអជាសត្តុវេទេហិបុត្របានទទួលព្រះធាតុមួយចំណែក គឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប (ព្រះចេតិយ ) ក្នុងក្រុងរាជគ្រឹះ ។

២.ពួកក្សត្រលិច្ឆវីបានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងវេសាលី ។

៣.ពួកក្សត្រអ្នកក្រុងកបិលវត្ថុ បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងកបិលវត្ថុ ។

៤.ពួកក្សត្រថូលិ អ្នកក្រុងអល្លកប្បៈ បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្រុងអល្លកប្បៈ ។

៥.ពួកក្សត្រកោឡិយៈ អ្នករាមគ្រាម បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងរាមគ្រាម ។

៦.ព្រាហ្មណ៍អ្នកវេដ្ឋទីបកៈ បានទទួលមួយចំណែកគឺ ២ នាឡិយកទៅបញ្ចុះក្នុងស្តូប ក្នុងដែនវេដ្ឋទីបកៈ ។

៧.ពួកមល្លក្សត្រក្រុងបាវា បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងក្រុងបាវា ។

៨.ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានទទួលមួយចំណែកគឺ ២ នាឡិ យកទៅបញ្ចុះក្នុងស្តូប ក្នុងក្រុងកុសិនារា ។

ក្នុងកាលណោះ ស្តេចសក្កទេវរាជទ្រង់រមិលមើលថា អ្នកណាយកចង្កូមកែវខាងស្តាំទៅ ? ក៏បានដឹងថា ទោណព្រាហ្មណ៍ជាអ្នកយកទុកក្នុងចន្លោះឈ្នួតក្បាល ក៏បានគិតថា ទោណព្រាហ្មណ៍នេះមិនអាចធ្វើសក្ការៈគោរពបូជាចំពោះព្រះចង្កូមកែវនេះបានទេ ហើយក៏យកចង្កូមកែវពីទោណព្រាហ្មណ៍នោះទៅ ។ ឯទោណព្រាហ្មណ៍កាលចែកព្រះធាតុអស់ហើយ ក៏យកដៃចាប់មើលចង្កូមកែវត្រង់ឈ្នួតក្បាល មិនឃើញ តែមិនអាចសួរថា អ្នកណាយកចង្កូមកែវទៅ ? ព្រោះខ្លួនជាម្ចាស់ចំណែកហើយ ។ ទោណព្រាហ្មណ៍គិតថា បើដូច្នោះអាត្មាអញ នឹងសូមតុម្ពនេះ ជំនួសចង្កូមកែវវិញ ។ ទើបពោលឡើងថា បពិត្រលោកដ៏ចំរើន ខ្ញុំសូមតុម្ពនេះទៅបញ្ចុះក្នុងស្តូប គ្រាន់បានធ្វើសក្ការៈគោរពបូជា ។ ព្រះរាជាទាំងឡាយក៏ព្រមអនុញ្ញាតឲ្យដល់ទោណព្រាហ្មណ៍នោះ ។ ចំណែកពួកក្សត្រមោរិយៈអ្នកក្រុងបិប្ផលិវ័ន មកសូមព្រះធាតុក្រោយគេ មិនបាន ក៏សូមយកព្រះអង្គារៈគឺធ្យូងយកទៅ ធ្វើស្តូប ទុកជាទីបូជាក្នុងក្រុងរបស់ខ្លួន ។

នៅក្នុងគម្ពីរពុទ្ធវិសរបស់ប្រទេសភូមា (ច្បាប់ឆដ្ឋសង្គាយនា ) មានបាលីប្រាកដពណ៌នាពីរឿងព្រះធាតុនេះ តែក្នុងគម្ពីរពុទ្ធវិសបិដកខ្មែរយើងលេខ ៧៧ គ្រាន់តែលើកយកបាលីពីបិដក ភូមាមកដាក់ជា លេខយោងត្រង់ទំព័រ ២៣៧ បន្ទាត់ទី ១០ ប៉ុណ្ណោះ។

ឯបាលីនោះថា ៖

ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ

អសម្ភិន្នា ឥមា សត្ត សេសា ភិន្នាវ ធាតុយោ ។

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញមាន ៧ អង្គគឺ ព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១ ព្រះទាឋធាតុ (ចង្កូមកែវ) ៤ ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត)២ ព្រះសារីរិកធាតុដ៏សេស ក្រៅពីនោះ សុទ្ធតែបែកចេញ (ជាចំណែកតូចៗ ) ។

មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា

ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ ។

ព្រះបរមធាតុទាំងឡាយមានខ្នាតផ្សេងៗគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំ មានទំហំប៉ុនគ្រាប់សណ្ដែកបាយបាក់ ព្រះធាតុខ្នាតកណ្ដាល មានទំហំប៉ុនកំណាត់គ្រាប់អង្ករបាក់ ព្រះធាតុខ្នាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ ។

មហន្តា សុវណ្ណវណ្ណា ច មុត្តវណ្ណា ច មជ្ឈិមា

ខុទ្ទកា មកុលវណ្ណា ច សោឡស ទោណមត្តិកា ។

ព្រះបរមធាតុទាំងឡាយ មានពណ៌ផ្សេងៗគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្ដាលមានពណ៌ដូចកែវមុក្តា

ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាម្លិះ រួមទាំងអស់ប្រមាណ ១៦ នាឡិ ស្មើ ១ ទោណ ។

មហន្តា បញ្ច នាឡិយោ  នាឡិយោ បញ្ច មជ្ឈិមា

ខុទ្ទកា ឆ នាឡី ចេវ  ឯតា សព្វាបិ ធាតុយោ។

ព្រះបរមធាតុសូម្បីទាំងអស់នុ៎ះគឺ ព្រះធាតុខ្នាតធំវាល់បាន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាលវាល់បាន ៥ នាឡិ ព្រះធាតុខ្នាតតូចវាល់បាន ៦ នាឡិ ។

នៅក្នុងគម្ពីរសុមង្គលវិលាសិនី អដ្ឋកថា មហាបរិនិព្វានសូត្រ បាន សំដែងថា ៖

កតិ បនស្ស ធាតុយោ វិប្បកិណ្ណា, កតិ ន វិប្បកិណ្ណាតិ ។ ចតស្សោ ទាឋា, ទ្វេ អក្ខកា, ឧណ្ហីសន្តិ ឥមា សត្ត ធាតុយោ ន វិប្បកិរឹសុ, សេសា វិប្បកិរឹសូតិ ។ តត្ថ សព្វខុទ្ទកា ធាតុ សាសបពីជមត្តា អហោសិ, មហាធាតុ មជ្ឈេ ភិន្នតណ្ឌុលមត្តា, អតិមហាតី មជ្ឈេ ភិន្នមុគ្គមត្តា។

ចុះព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធបរមសាស្តា បែកជាចំណែកប៉ុន្មាន ? មិនបែកប៉ុន្មានដែរ ? ។ ព្រះបរមធាតុព្រះសម្មាសម្ពុទ្ធនៃយើងមិនបែកជាចំណែកតូចមាន ៧ នេះគឺ ព្រះចង្កូមកែវ ៤ ដងកាំបិត ២ ថ្ងាស ១ ឯព្រះធាតុដ៏សេសក្រៅពីនោះសុទ្ធតែបែកជាចំណែកតូច ៗ ។ បណ្តាព្រះធាតុទាំងនោះ ព្រះធាតុតូចបំផុតប៉ុនគ្រាប់ស្ពៃ, ព្រះធាតុខ្នាតកណ្តាលប៉ុនគ្រាប់អង្ករបាក់ពាក់កណ្តាល, ព្រះធាតុខ្នាតធំបំផុតប៉ុនគ្រាប់សណ្តែកបាយបាក់ពាក់កណ្តាល ។

## <u>ខ្នាត ពណ៌ និង បរិមាណ របស់សម្ពិន្ទធាតុ</u>

### ព្រះធាតុខ្នាតធំ

**១.ខ្នាត** គ្រាប់សណ្តែកបាយ

**២.ពណ៌** ពណ៌មាស

**៣.បរិមាណ** ៥ នាឡិ

### ព្រះធាតុខ្នាតកណ្តាល

**១.ខ្នាត** ប៉ុនគ្រាប់អង្ករបាក់

**២.ពណ៌** កែវមុក្តា

**៣-.បរិមាណ** ៥ នាឡិ

## ព្រះធាតុខ្លាគតូច

**១.ខ្នាត** *ប៉ុនគ្រាប់ស្ពៃ*

**២.ពណ៌** *ដូចផ្កាម្ទេះក្រពុំ*

**៣.បរិមាណ** *៦ នាឡិ ។*

*មានអ្នកសាកសួរថា ហេតុអ្វីទើបព្រះធាតុរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានបំណែកបែកជាចំណែកតូចៗយ៉ាងនេះ ? ប្រស្នានេះ លុះណាតែ យើងសិក្សាពីព្រះគុណរបស់ព្រះសម្ពុទ្ធ ដែលព្រះអង្គទ្រង់មានសព្វញ្ញុ-តញ្ញាណ ទ្រង់មានព្រះទ័យករុណាចំពោះសត្វលោកយ៉ាងណា ដូចព្រះអង្គ ទ្រង់សឹងលើគ្រែបរិនិព្វាន ទ្រង់បានអធិដ្ឋានឲ្យព្រះធាតុបែកជាចំណែកតូចៗ (ជិនកាលមាលីបករណ៍ ១/៣៩)ថា* អហំ ន ចិរំ ឋត្វា បរិនិព្វាយិស្សាមិ មយ្ហំ សាសនំ ន តាវ សព្វត្ថ វិត្ថារិកំ តស្មា បរិនិព្វុតស្សាបិ សាសបមត្តម្បិ ធាតុំ គហេត្វា អត្តនោ អត្តនោ វសនដ្ឋានេ ចេតិយំ កត្វា បរិចរន្តោ មហាជនោ សគ្គបរាយនោ ហោតូតិ ធាតុវិកិរត្ថំ អធិដ្ឋាសិ ។ តស្មា វិប្បកិណ្ណា ច ន វិប្បកិណ្ណា ច ។ តថាគតមិនស្ថិតនៅយូរអង្វែងទេ នឹងបរិនិព្វានទៅ សាសនាតថាគតនៅមិនទាន់ផ្សាយទៅគ្រប់ទីកន្លែងនៅឡើយ ព្រោះហេតុនោះ កាលបើតថាគតបរិនិព្វានទៅហើយ មហាជនទទួលយកនូវព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃ ហើយធ្វើចេតិយក្នុងទីនៅរបស់ខ្លួនៗ ហើយគោរពបូជា កាលត្រាច់ទៅនឹងមានសួគ៌ក្នុងខាងមុខ ។ ព្រោះហេតុនោះ ព្រះធាតុបែកចេញជាចំណែកតូចៗខ្លះ មិនបែកចេញខ្លះ ។

ព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គទ្រង់បំពេញពុទ្ធចរិយាអស់ ៤៥ វស្សា ដើម្បីប្រយោជន៍ដល់សត្វលោក សូម្បីព្រះអង្គទ្រង់បរិនិព្វានទៅហើយ ក៏ព្រះអង្គនៅតែបំពេញប្រយោជន៍ដល់សត្វលោកទៀត ដូចព្រះអង្គទ្រង់អធិដ្ឋានឲ្យព្រះធាតុបែកជាចំណែកតូចៗ ដើម្បីផ្សាយទៅគ្រប់ទីកន្លែងទុកជាគ្រឿងសក្ការៈគោរពបូជារបស់ពុទ្ធបរិស័ទ នឹងបានសម្រេចនូវស្ថានសួគ៌និងព្រះនិព្វានក្នុងកាលខាងមុខ ។

(អដ្ឋកថា ទីឃនិកាយ មហាវគ្គ ៥/៣៤៧ )

ក្រោយពីព្រះបរមសារីរិកធាតុ ត្រូវបានតម្កល់ទុកក្នុងព្រះចេតិយទាំង ៨ ហើយ ។ មនុស្ស ទេវតានាំគ្នាធ្វើសក្ការៈគោរពបូជាចំពោះព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធតៗគ្នា ។ មិនយូរប៉ុន្មានផង ស្រាប់តែទឹកដីជម្ពូទ្វីប មានសង្គ្រាមកើតឡើង ។ ពេលនោះ ព្រះមហាថេរៈ ព្រះនាមកស្សបៈបានណែនាំព្រះបាទអជាតសត្តុ ឲ្យធ្វើព្រះចេតិយខាងក្នុងដី ដើម្បីប្រមូលព្រះបរមសារីរិកធាតុមកប្រតិស្ឋានទុកក្នុងចេតិយនោះ ដើម្បីរក្សាឲ្យគង់វង្សអស់កាលជាយូរអង្វែង ។ កាលសាងស្តូបចេតិយស្រេចហើយកាលណា ព្រះមហាកស្សបៈចូលឈានទៅអារាធនាព្រះបរមសារីរិកធាតុ ក្នុងព្រះចេតិយទាំងអស់ វៀរលែងតែចេតិយរាមគ្រាមចេញ ។

ព្រះបរមសារីរិកធាតុ ត្រូវធ្វើជាតុនិធានប្រតិស្ឋានទុកក្នុងស្តូបចេតិយអស់កាលដ៏យូរ ទើបមកដល់រជ្ជសម័យព្រះបាទអសោកមហារាជ ក្នុងពុទ្ធសតវត្សរ៍ទី ៣ ទើបព្រះរាជាអង្គនេះ បានអារាធនាព្រះបរមធាតុចេញពីស្តូបចេតិយក្នុងដី មកកសាងព្រះចេតិយក្នុងជម្ពូទ្វីប ទុកជាទីសក្ការៈបូជា ។

ក្នុង ព.ស.២៣៦ ព្រះមហិន្ទត្ថេរៈ ជាឱរសរបស់ព្រះបាទអសោកមហារាជ បានមកផ្សព្វផ្សាយព្រះពុទ្ធសាសនា ក្នុងកោះស្រីលង្កា ។ លុះចេញវស្សាហើយ ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ កត្តិក ព្រះថេរៈមានបំណងទៅក្រាបថ្វាយបង្គំព្រះបរមសារីរិកធាតុ និងស្រីមហាពោធិ ឯជម្ពូទ្វីបវិញ ។ ក្នុងកាលណោះ ព្រះរាជាទេវានម្បិយតិស្សៈ សូមឲ្យសុមនសាមណេរទៅអារាធនាព្រះបរមសារីរិកធាតុមកកោះស្រីលង្កា ដើម្បីទុកជាទីសក្ការៈ ។ សុមនសាមណេរបានទៅសុំអារាធនាព្រះបរមសារីរិកធាតុពីស្តេចអសោកមហារាជ ។ ព្រះបាទអសោកបានប្រគល់នូវព្រះធាតុជាច្រើនដាក់ក្នុងបាត្ររបស់សុមនសាមណេរ ។ បន្ទាប់មកសុមនសាមណេរបានទៅអារាធនាព្រះអក្ខកធាតុ (ដងកាំបិតស្មាខាងស្តាំ) ពីសក្កទេវរាជ មកកាន់កោះស្រីលង្កា ។ ព្រះអក្ខកធាតុបានប្រតិស្ឋានទុកក្នុងព្រះចេតិយថូបារាម ។ ចំណែកព្រះធាតុដែលបានទទួលពីស្តេចអសោក បានប្រតិស្ឋានតាមចេតិយនានាក្នុងអនុរាធបុរៈ ។ ព្រះបរមសារីរិកធាតុ ដែលសុមនសាមណេរអារាធនាមកពីស្តេចអសោកនោះ ត្រូវស្ថិតនៅក្នុងស្តូបចេតិយនានាអស់កាលដ៏យូរ ។ លុះខាងក្រោយមកស្តូបចេតិយនោះ ចាស់ទ្រុឌទ្រោម ក៏នាំគ្នាធ្វើការរុះរើ ដើម្បីកសាងថ្មីឡើងវិញ ។ ពេលរុះរើស្តូបចេតិយចាស់នេះ ក៏ប្រទះឃើញកោដ្ឋថ្ម ដែលមានព្រះបរមសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ហើយក៏នាំមកថែរក្សាទុកជាទីសក្ការៈបូជារបស់ពុទ្ធសាសនិកជន ។

ក្នុងថ្ងៃ សៅរ៍ ៧ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី ២០ ខែ កុម្ភៈ គ.ស.២០១០ គណៈធម្មយាត្រានៃពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលដឹកនាំដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ (ធម្មានន្ទ) បូលទៅនមស្ការ និងទស្សនាភ្នំមិស្សកបព៌ត ដែលជាទីកន្លែងព្រះមហិន្ទត្ថេរ

ជាដើម និមន្តពីជម្ពូទ្វីបមកគង់ផ្សព្វផ្សាយព្រះពុទ្ធសាសនា ។ គណៈធម្មយាត្រា បានចូលទៅថ្វាយបង្គំព្រះបរមសារីរិកធាតុ ដែលបានពីស្តូបចេតិយចាស់ ដោយបីតិបាមោជ្ជ ប្រកបដោយសោមនស្សរីករាយខ្លាំងណាស់ ។ ខណៈពេលនោះ ព្រះគ្រូចៅអធិការវត្តមហិន្ទលេ បានជូននូវព្រះបរមសារីរិកធាតុនោះមួយអង្គ ដល់ខ្ញុំព្រះករុណា ខ្ញុំបាទ (ធម្មានន្ទ) អារាធនាមកប្រទេសកម្ពុជាទុកជាទីសក្ការៈគោរពបូជា ។

ព្រះបរមសារីរិកធាតុមួយអង្គនេះ បានមកដល់ប្រទេសកម្ពុជានៅវេលាម៉ោង ៩:០០ នាទីព្រឹក ក្នុងថ្ងៃ សៅរ៍ ១៤ កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី ២៧ ខែ កុម្ភៈ គ.ស.២០១០ ។

ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលមានលោកបណ្ឌិត **ភុល ឆេង** ជាប្រធាន បានព្រមព្រៀងជាមួយពុទ្ធបរិស័ទគ្រប់ទិសទីប្រារព្ធកម្មវិធីបុណ្យទទួលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ក្នុងថ្ងៃ សៅរ៍-អាទិត្យ ៥-៦ កើត ខែ ចេត្រ ឆ្នាំ ឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី ២០-២១ ខែ មីនា គ.ស.២០១០ ។

ដោយគុណានុភាពនៃព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាអម្ចាស់
សូមសត្វលោកបានជួបប្រសព្វនូវសេចក្តីសុខ គ្រប់កាលទៅហោង។

# នមស្ការព្រះបរមសារីរិកធាតុ

១.មហាគោតមោ ជិនវរោ កុសិនារម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ ។

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ សារីរិកធាតុ ព្រះមហាគោតម
ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ ជិតបុរីរម្យ ក្រុងកុសិនារា ។
កិរិយាផ្សាយនូវ ព្រះធាតុនានា ផ្សេង ៗ ពីគ្នា ក្នុងទីទាំងឡាយ
ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ ព្រះធាតុទាំងឡាយ គ្រប់ទីនោះ ៗ។

២.ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ
អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ ។

ព្រះសារីរិកធាតុ ល្អស្អាតទាំងឡាយ ដែលមិនបែកសោះ ប្រាំពីរព្រះអង្គ
គឺព្រះឧណ្ហិ-សធាតុបញ្ចង់[១] មានមួយព្រះអង្គ នៅគង់ល្អស្អាត
និងព្រះទាឋា[២] សារីរិកធាតុ ទាំង៤អង្គស្អាត គ្មានឃ្លាតបែកចេញ
ព្រះអក្ខកធាតុ[៣] នៅស្អាតពេញលេញ គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ
ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់ ប្រាំពីរព្រះអង្គ គង់នៅទាំងអស់
ព្រះសារីរិកធាតុ ដ៏សេសពីនោះ បែកចេញចំពោះ ចំណែកធំតូច ។

៣.មហន្តា មុគ្គមត្តា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ ។

ព្រះសារីរិកធាតុ នៃព្រះភគវា មានពណ៌ផ្សេងគ្នា ទាំងបីវិលាស

---

១ ឆ្អឹងថ្ងាស ។ ២ ព្រះចង្កូមកែវ ។ ៣ ឆ្អឹងដងកាំបិត ។

ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ពន្លឺឱភាស វិសេសពេកក្កាត់ ។
ព្រះធាតុកណ្ដាល វិលាសដូចរ័តន៏ មុក្តាប្រាកដ ស្មើរចាប់ច្រឡំ
ព្រះធាតុខ្នាតតូច ដូចផ្កាម្លិះសម ពណ៌សស្រគាំ ក្រពុំស្រស់ស្អាត
សរុបព្រះធាតុ នៃព្រះសាស្ដា លោកបានពោលថា បើគិតតាមខ្នាត
ដប់ប្រាំមួយនាឡិ មិនបាត់បង់ខាត ទំហំប៉ុនខ្នាត ចំនួនមួយទោណ ។

**៥. មហន្តា បញ្ច នាឡិយោ នាឡិយោ បញ្ច មជ្ឈិមា**
**ខុទ្ទកា ឆ នាឡី ចេវ ឯតា សព្វាបិ ធាតុយោ ។**

ព្រះបរមធាតុ មុនីនាថសាស្ដា ទាំងអស់នោះណា បែកជាតូចធំ
លោកបានពោលទុក ថាមានទំហំ មានតូចមានធំ មានខ្នាតកណ្ដាល ។
ព្រះធាតុខ្នាតធំ ចំនួនប្រាំនាឡិ ព្រះធាតុកណ្ដាល ប្រាំនាឡិប្រាកដ
ព្រះធាតុខ្នាតតូច ប្រាំមួយនាឡិគត់ តាមលោកកំណត់ បីយ៉ាងដូច្នេះ ។

## មង្គល ១០៨ ក្នុងស្នាមព្រះបាទ

អរុណក្រហមមានឡើង ជាបុព្វភាគនៃការរះឡើងរបស់ព្រះអាទិត្យយ៉ាងណា បុព្វនិមិត្តរមែងប្រាកដឡើងចំពោះពុទ្ធុប្បាទ ក៏យ៉ាងនោះ ពោលគឺ មុនពុទ្ធកាលមួយពាន់ឆ្នាំ ព្រហ្មជាន់សុទ្ធាវាសបានក្លែងភេទជាព្រាហ្មណ៍មកកាន់មនុស្សលោកហើយប្រកាសថា ព្រះពុទ្ធជាម្ចាស់នឹងឧបត្តិឡើងក្នុងលោកនេះ បន្ទាប់ពីនេះទៅមួយពាន់ឆ្នាំទៀត[២] ។ ព្រហ្មជាន់សុទ្ធាវាសនោះបានតែងគម្ពីរមហាបុរិសលក្ខណៈ ដែលរៀបរាប់ពីលក្ខណៈ ៣២ ប្រការរបស់ព្រះពុទ្ធ ឬស្ដេចចក្រពត្តិ ដោយមានគាថាមួយម៉ឺនពីរពាន់តម្កល់ទុកក្នុងគម្ពីរត្រៃវេទ ។ បណ្ដាគាថាទាំងនោះ គាថា១,០១៦ បទហៅថា ពុទ្ធមន្តដែលសម្ដែងលក្ខណៈរបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ អគ្គសាវក មហាសាវក ពុទ្ធបិតា ពុទ្ធមាតាជាដើម ។

ហេតុនោះ ព្រះបាទសុទ្ធោទនៈជាព្រះពុទ្ធបិតាបានអញ្ជើញព្រាហ្មណ៍បែកធ្លាយក្នុងត្រៃវេទមកមើលលក្ខណៈរបស់ព្រះពោធិសត្វ ដែលទើបតែប្រសូតមកមានកោណ្ឌញ្ញព្រាហ្មណ៍ជាដើម ។ សូម្បីព្រាហ្មណ៍បែកធ្លាយក្នុងត្រៃវេទ ក្នុងសម័យពុទ្ធកាល ដូចជា បោក្ខរសាតិ សោណទន្តៈ កូដទន្តៈ និងព្រហ្មាយុជាដើម បានពិនិត្យមើលលក្ខណៈព្រះពុទ្ធជាម្ចាស់មុន ទើបព្រមជឿជាក់ថា ពិតជាព្រះពុទ្ធពិតប្រាកដមែន ។ ក្រោយពីព្រះពុទ្ធជាម្ចាស់ទ្រង់បរិនិព្វាន គម្ពីរមហាបុរិសលក្ខណៈ ក៏អន្តរធានបាត់ទៅតាមកាលវេលា ។

---

១ បរមត្ថជោតិកា អដ្ឋកថា មង្គលសូត្រ ។

យ៉ាងណាក៏ដោយ សេចក្ដីជាប់ទាក់ទងនឹងមហាបុរិសលក្ខណៈ ឬ ពុទ្ធលក្ខណៈដែលប្រាកដក្នុងព្រះសូត្រ ៣ កន្លែងគឺ មហាបទានសូត្រ ក្នុងទីឃនិកាយ មហាវគ្គ[១], លក្ខណសូត្រ ក្នុងទីឃនិកាយ បាដិកវគ្គ[២], និងមាន ក្នុងព្រហ្មាយុសូត្រ ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ[៣], ។ ក្រៅពីនេះ នៅមានពោលទុកក្នុងពុទ្ធប្បវត្តិ ចំណែកមហាយានឈ្មោះ លលិតវិសតរៈ ដូចគ្នា[៤] ។

ក្នុងមហាបុរិសលក្ខណៈ ៣២ នេះ មានលក្ខណៈមួយដែលបញ្ជាក់ពីស្នាមព្រះបាទ ដែលមានកងចក្រ និង កាំ ១,០០០ ដូចសេចក្ដីក្នុងលក្ខណសូត្រ[៥]ថា ៖

បុន ច បរំ ភិក្ខវេ មហាបុរិសស្ស ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ ហោន្តិ សហស្សារានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ ។ យម្បិ ភិក្ខវេ មហាបុរិសស្ស ហេដ្ឋាបាទ-តលេសុ ចក្កានិ ជាតានិ ហោន្តិ សហស្សារានិ សនេមិកានិ សនាភិកានិ សព្វាការបរិបូរានិ, ឥទម្បិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណំ ភវតិ ។

១ ទីឃ.មហា.១៦/៣៤ ។ ២ ទីឃ.បាដិក.១៨/៣ ។ ៣ មជ្ឈិម.មជ្ឈិម.២៥/៨ ។ ៤ លលិត-វិស្តរៈ ១/៥៩៩ ។ ៥ ទីឃ.បាដិក.១៩/៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១,០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់និងដុំព្រមទាំងកាំ ១,០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។

## មង្គលជួបក្នុងព្រះសូត្រ

ក្នុងព្រះសូត្រខាងដើមមិនបានពោលដល់រូបសញ្ញលក្ខណៈ ក្នុងស្នាមព្រះបាទ ហៅថា **មង្គល** ។ តែក្នុងព្រះសូត្រដទៃ មានការពោលដល់មង្គលទុកច្រើនប្រការ ដូចព្រះនាងបជាបតិគោតមីក្រាបទូលថា[១] ៖

ចក្កង្កុសធជាកិណ្ណេ ចារេ កមលកោមលេ
បសារេហិ បណាមំ តេ ករិស្សំ បុត្ត ឧត្តមេ ។

សូមព្រះអង្គសណ្ដូកនូវព្រះបាទទាំងគូ ដ៏ទន់ល្វន់ដូច
ផ្កាឈូក ដេរដាសដោយស្នាមចក្រ កង្វេរ និងទង់
ខ្ញុំព្រះអង្គមានសេចក្ដីស្រឡាញ់ចំពោះព្រះឱរស
នឹងថ្វាយបង្គំព្រះបាទាទាំងគូនោះ ។

១ ខុទ្ទក.អប.៧៦/៤៩ ។

កាលព្រះសម្មាសម្ពុទ្ធទ្រង់យាងទៅប្រោសញាតិក្នុងក្រុងកបិលពស្តុ ព្រះនាងយសោធរាត្រាស់ចំពោះព្រះពុទ្ធជាម្ចាស់ ដល់រាហុលកុមារថា ៖

ចក្កវរង្កិតរត្តសុបាទោ លក្ខណមណ្ឌិតអាយតបណ្ហិ
ចាមរឆត្តវិភូសិតបាទោ ឯស ហិ តុយ្ហំ បិតា នរសីហោ[១] ។

ព្រះអង្គមានព្រះបាទក្រហមព្រឿងៗ ប្រកបព្រមដោយកងចក្រ ដ៏ប្រសើរ មានកែងព្រះបាទវែង ប្រដាប់ដោយលក្ខណៈផ្សេងៗ មានស្នាមព្រះបាទប្រដាប់ដោយចាមរ និងឆត្រ នរសីហៈអង្គនោះ ជាព្រះរាជបិតារបស់កូន ។

ក្នុងគម្ពីរពុទ្ធវំសបានសម្តែងរូបសញ្ញាលក្ខណៈ ៥ ប្រការគឺ ទង់ជ័យ កែវវជីរ ទង់ជ្រុង រូបថាសដាក់គ្រឿងសំណែន និងកង្វេរ ដូច្នេះថា ៖

គាយន្តិ សេឡេន្តិ ច វាទយន្តិ ច
ភុជានិ បោថេន្តិ ច នច្ចយន្តិ ច
មុញ្ចន្តិ បុប្ផំ បន បញ្ចវណ្ណិកំ
មន្ទារវំ ចន្ទនចុណ្ណមិស្សិតំ ។

យថា តុយ្ហំ មហាវីរ បាទេសុ ចក្កលក្ខណំ
ធជវជិរបដាកា វឌ្ឍមានង្កុសាចិតំ[២] ។

---

១ អដ្ឋកថា ខុទ្ទក.ជាតក ឯកកនិបាត ។ ២ ខុទ្ទក.ពុទ្ធវំស ៧៧៖១៣ ។

ទេវតាទាំងឡាយ ច្រៀង ហួច ប្រគំ ទះដៃ រាំ ជម្រុះផ្កា មន្ទារវៈ មានពណ៌ ៥ ដែលលាយឡំ ដោយលម្អិត នៃខ្លឹមចន្ទន៍ ។

(ហើយពោលថា) បពិត្រព្រះអង្គមានព្យាយាមធំ លក្ខណៈនៃចក្រ ទង់ជ័យ កែវវជីរ ទង់ជ្រុង រូបថាសដាក់គ្រឿងសំណែនទិងកង្វេរ រមែងស្រស់ស្អាត ។

(គាថានេះ មានការប្រែខុសពីក្រុមជំនុំព្រះត្រៃបិដក ដែលបានប្រែហើយ ។ ឃើញថា ក្រុមជំនុំប្រែភ្លាំងភ្លាត់ មិនត្រឹមត្រូវតាមអដ្ឋកថាពន្យល់ សេចក្ដីឲ្យប្រែ ។ ក្នុងគម្ពីរខុទ្ទកនិកាយ ពុទ្ធវំស ៧៧/១៣ ប្រែថា

បពិត្រព្រះអង្គមានព្យាយាមធំ លក្ខណៈនៃចក្រ ទង់ជ័យ កែវវជីរ ទង់ជ្រុង គាក់តែងដោយកង្វេរ កំពុងរីកចម្រើនត្រង់ព្រះបាទទាំងគូរបស់ព្រះអង្គ ។

ក្នុងអដ្ឋកថាពុទ្ធវំសខែគាថានេះថា ៖

**ធជវជិរបដាកា វឌ្ឍមានង្កុសាចិតន្តិ** ធជេន ច វជិរេន ច បដាកាយ ច វឌ្ឍមានេន ច អង្កុសេន ច អាចិតំ អលង្កតំ បរិវារិតំ ចានេសុ ចក្កលក្ខណន្តិ អត្ថោ។

បណ្ដាបទទាំងឡាយ បទថា **ធជវជិរបដាកា វឌ្ឍមានង្កុសាចិតំ** មានសេចក្ដីអធិប្បាយថា លក្ខណៈនៃចក្រក្នុងព្រះបាទទាំងឡាយ ដែល

ស្រស់ ស្អាត ល្អ ដោយទង់ជ័យផង ដោយកែវវជីរផង ដោយទង់ជ្រុងផង រូបថាសដាក់គ្រឿងសំណែនផង ដោយកង្វេរផង ។

សរុបសេចក្តីក្នុងព្រះសូត្រខាងដើមពោលដល់មង្គល ៧ ប្រការទុកក្នុងស្នាមព្រះបាទគឺ

១.រូបទង់ជ័យ (ធជ)

២.រូបទង់ជ្រុង (បដាក)

៣.រូបផ្ចិតកន្ទុយចាមរី (វាលវិជនី)

៤.រូបឆត្រ (ឆត្ត)

៥.រូបកែវវជីរ (វជិរ)

៦.រូបថាសដាក់គ្រឿងសំណែន (វឌ្ឍមាន)

៧.រូបកង្វេរ (អង្កុស)

**មង្គលដែលជួបក្នុងអដ្ឋកថាព្រះសូត្រ**

គម្ពីរអដ្ឋកថារបស់មហាបទានសូត្រ រចនាដោយព្រះពុទ្ធឃោសាចារ្យ ប្រហែលចុងពុទ្ធសតវត្សរ៍ទី ៩ ដោយបរិវត្តពីគម្ពីរមហាអដ្ឋកថា ដែលជាបកិណ្ណកទេសនារបស់ព្រះពុទ្ធជាម្ចាស់ និងពាក្យអធិប្បាយរបស់ព្រះសាវ័កបានពោលដល់មង្គល ៣៩ ប្រការគឺ ៖

១.សត្តិ រូបលំពែង

២.សិរិវច្ឆោ រូបផ្ទះកំពូល

៣.នន្ទិ រូបផ្កាចន្ទ

៤.សោវត្ថិកោ រូបសោវត្ថិកៈ

៥.វដំសកោ រូបផ្កាឈើក្រងលើសីសៈ

៦.វឌ្ឍមានកំ រូបថាសដាក់គ្រឿងសំណែន

៧.មច្ឆយុគលំ រូបត្រីគូ

៨.ភទ្ទបីឋំ រូបតាំងមាស

៩.អង្កុសកោ រូបកង្វេរ

១០.ធាសាទោ រូបប្រាសាទ

១១.តោរណំ រូបសសរបង្គោល

១២.សេតច្ឆត្តំ រូបស្វេតច្ឆត្រ

១៣.ខគ្គោ រូបព្រះខ័ន

១៤.តាលវណ្តំ រូបផ្ចិតស្លឹកត្នោត

១៥.មោរហត្ថកោ រូបផ្ចិតកន្ទុយក្ងោក

១៦.វាឡវីជនី រូបផ្ចិតកន្ទុយចាមរី

១៧.ឧណ្ហីសំ រូបក្បាំង

១៨.មណិ រូបកែវមណី

១៩.បត្តោ រូបបាត្រ

២០.សុមនទាមំ រូបកម្រងផ្កាម្លិះ

២១.នីលុប្បលំ រូបផ្កាព្រលិតខៀវ

២២.រត្តុប្បលំ រូបព្រលិតក្រហម

២៣.សេតុប្បលំ រូបផ្កាព្រលិតស

២៤.បទុមំ រូបផ្កាឈូក

២៥.បុណ្ឌរីកំ រូបផ្កាឈូកស

២៦.បុណ្ណឃដោ រូបឆ្នាំងទឹកពេញ

២៧.បុណ្ណចាតិ រូបថាសដាក់ទឹកពេញ

២៨.សមុទ្ទោ រូបសមុទ្រ

២៩.ចក្កវាឡោ រូបចក្កវាឡ

៣០.ហិមវា រូបភ្នំហេមពាន្ត

៣១.សិនេរុ រូបភ្នំសិនេរុ

៣២-៣៣.ចន្ទិមសូរិយា រូបព្រះចន្ទ និងព្រះអាទិត្យ

៣៤.នក្ខត្តានិ រូបផ្កាយនក្ខត្តឫក្ស

៣៦-៣៨.ចត្តារោ មហាទីបា, ទ្វិបរិត្តទីបសហស្សានិ *រូបទ្វីបធំ ទាំង ៤ និងទ្វីបតូច ២,០០០*

៣៩.ចក្កវត្តិវេញ្ញោ បរិសំ *រូបបរិវាររបស់ស្តេចចក្រពត្តិ ។*

*មង្គល ៣៩ ប្រការដែលជួបក្នុងអដ្ឋកថាដូចពោលមកនេះ កាលរាប់រួមគ្នានូវមង្គលដែលមិនជាន់គ្នាក្នុងព្រះសូត្រគឺ ទង់ជ័យ និងទង់ជ្រុង មានចំនួន ៤១ ប្រការ ។ ដោយមិនរាប់កែវវេជីរចូលផង ព្រោះកែវវេជីរស្ថិតនៅក្នុងរតនៈទាំង ៧ ទើបគួររាប់បញ្ចូលក្នុងកែវមណី ។*

## ***មង្គល ១០៨ ប្រការ តាមគម្ពីរអដ្ឋកថារបស់អនាគតវង្ស ជិនាលង្ការដីកា និងបាទវន្ទនា***

*គម្ពីរអដ្ឋកថារបស់អនាគតវង្សដែលរចនាក្នុងពុទ្ធសតវត្សរ៍ទី ១០ ក្នុងរជ្ជសម័យ ព្រះបាទធាតុសេន និងជិនាលង្ការដីកាដែលរចនាក្នុងពុទ្ធសតវត្សរ៍ទី ១៧ ពោលដល់មង្គល ១០៨ ប្រការ ។ កាលពិចារណាប្រៀបធៀបគ្នាក៏ជួបថា លំដាប់មង្គលខ្លះក្នុងគម្ពីរទាំងពីរផ្សេងគ្នា ។ កាលផ្សេងគ្នាខ្លះនេះ កើតពីការចារតៗគ្នាមក ធ្វើឲ្យមានការឃ្លៀងឃ្លាតចាកច្បាប់ដើម ។*

*ក្រៅពីនេះ មានគាថានមស្ការព្រះពុទ្ធជាម្ចាស់ ដែលពោលដល់មង្គល ១០៨ ក្នុងស្នាមព្រះបាទ ឈ្មោះ* ***បាទវន្ទនា*** *តែងដោយមហាមាត្យ ស្រីចតុរង្គពល ក្នុងរជ្ជសម័យព្រះបាទសីហសូរ (ព.ស.១៨៩៤-១៩០៤) ជាក្សត្រអង្គទី ៤ នៃរាជវង្សបិនយៈ ប្រទេសភូមា ។* ***បាទវន្ទនា****នេះបានផ្សាយចូលមកដល់ស្រុកខ្មែរ ដោយប្រាកដឈ្មោះថា* ***អដ្ឋុត្តរសតមង្គលគាថា*** *។*

សេចក្តីក្នុងគម្ពីរអដ្ឋកថារបស់អនាគតវង្ស មានដូច្នេះ ៖

តានិ បន សហា កម្មានិសំសេហិ វណ្ណយិស្សាម ។ មហាបុរិសោ បន បារមីភូមិយំ ទានាទីសុ បុញ្ញកម្មេសុ ទឡ្ហសមាទានោ អហោសិ ។ តេន សុប្បតិដ្ឋិតបាទលក្ខណំ និព្វត្តិស្សតិ ។ បរេហិ អវិក្ខម្ភិយភាវោ តទានិសំសោ ។សត្តានំ បន ឧប្បន្នំ ភយំ ទិស្វា អារក្ខំ អកាសិ ។ បរិវារំ កត្វា ទានំ អទាសិ ។ តេនស្ស បាទេសុ ចក្កលក្ខណំ និព្វត្តិស្សតិ ។ បរិវារេត្វា អនេកានិ មង្គលានិ និព្វត្តិស្សន្តិ ។ សេយ្យថិទំ ។ សត្តិ, សិរីវច្ឆោ, នន្ទិយាវដ្តំ, សោវត្ថិកំ, វដំសកំ, វឌ្ឍមានំ, ភទ្ទបីឋំ, អង្កុសោ, បាសាទោ, តោរណំ, សេតច្ឆត្តំ, ខគ្គំ, តាលវណ្ដំ, មោរហត្ថំ, ឧណ្ហីសំ, បត្តំ, មណិ, សុមនទាមំ, បទុមំ, រត្តុប្បលំ, សេតុប្បលំ, នីលុប្បលំ, រត្តបុណ្ឌរីកំ, សេតបុណ្ឌរីកំ, បុណ្ណឃដោ, បុណ្ណបាតិ, សមុទ្ទោ, ចក្កវាឡំ, ហិមវា, មេរុ, សុរិយោ, ចន្ទិមា, នក្ខត្តំ, ចតុរោ មហាទីបា បរិត្តទីបា, សបរិសោ ចក្កវត្តិ, ទក្ខិណាវត្តសេតសង្ខោ, សុវណ្ណមច្ឆយុគឡំ, ចក្កំ, សត្ត មហាគង្គា, សត្ត មហាសេលា, សត្ត មហាសរា, សុបណ្ណរាជា, សុសុមារកោ,

ធជបដាកំ, រតនចាដង្គី, សុវណ្ណវាលវីជនី, កេលាសបព្វតោ, សីហរាជា, ព្យគ្ឃរាជា, វលាហកោ អស្សរាជា, ឧបោសថវារណរាជា, ឆទ្ទន្តហត្ថី, វាសុកី ឧរគរាជា, ហំសរាជា, ឧសភរាជា, ឯរាវណោ នាគរាជា, សុវណ្ណមករោ, ចតុមុខា សោវណ្ណនាវា, សវច្ឆកា គាវី, កិន្នរោ, កិន្នរី, ករវីកោ, មយូររាជា, កោញ្ចរាជា, ចក្កវាករាជា, ជីវញ្ជីវករាជា, ឆ កាមាវចរទេវលោកា, សោឡស ព្រហ្មលោកាតិ អដ្ឋុត្តរសតមង្គលានិ និព្វត្តិស្សន្តីតិ ។ ពហុបរិវារភាវោ តទានិសំសោ ។

*ម្យ៉ាងទៀត ខ្ញុំនឹងពណ៌នាពុទ្ធលក្ខណៈទាំងនោះ ព្រមដោយកម្មនិងអានិសង្ស ។ ព្រះមហាបុរសជាអ្នកសមាទានយ៉ាងមាំទាំក្នុងកុសលកម្មមានទានជាដើម ក្នុងរយៈបំពេញបារមី ។ ព្រោះហេតុនោះ ព្រះលក្ខណៈដែលមានព្រះបាទប្រតិស្ឋានដ៏ល្អ (រាបស្មើ) បានកើតឡើង ភាវៈដែលអ្នកដទៃគ្របសង្កត់មិនបាន ជាអានិសង្សនៃការសមាទានដ៏មាំទាំក្នុងកុសលធម៌នោះ ។*

*ព្រះអង្គទ្រង់ឃើញភ័យដែលកើតឡើងដល់សត្វលោក ហើយទ្រង់បានឲ្យទានព្រមទាំងបរិវារ ដូច្នោះ ចក្កលក្ខណៈក៏បានកើតឡើងក្នុងព្រះបាទរបស់ព្រះអង្គ និងមង្គលជាច្រើនក៏បានកើតឡើងឡោមពទ្ធគឺ លំពែង រូប*

ផ្ទះកំពូល រូបផ្កាចន្ទ្ធ រូបសវត្ថិកៈ រូបផ្កាឈើក្រងលើសីសៈ រូបថាសដាក់គ្រឿងសំណែន រូបតាំងមាស រូបកង្វេរ រូបប្រាសាទ រូបសសរបង្គោល រូបស្វេតច្ឆត្រ រូបព្រះខ័ន រូបផ្ចិតស្លឹកត្នោត រូបផ្ចិតកន្ទុយក្ងោក រូបក្បាំង រូបបាត្រ រូបកែវមណី រូបភួងផ្កាម្ទិះ រូបផ្កាបទុម  រូបព្រលឹតក្រហម (រំចង់) រូបព្រលឹតស រូបព្រលឹតខៀវ រូបផ្កាឈូកក្រហម រូបផ្កាឈូកស រូបថ្នាំងដាក់ទឹកពេញ រូបថាសដាក់ទឹកពេញ រូបមហាសមុទ្រ រូបភ្នំចក្កវាឡ រូបភ្នំហេមពាន្ត រូបភ្នំសិនេរុ រូបព្រះអាទិត្យ រូបព្រះចន្ទ រូបផ្កាយនក្ខត្តឫក្ស រូបទ្វីបធំទាំង ៤ ព្រមទាំងទ្វីបតូច រូបព្រះចៅចក្រពត្តិ និងរូបបរិវារ រូបសង្ខសវិលទៅខាងស្តាំ រូបត្រីមាសមួយគូ រូបកងចក្ក រូបស្ទឹងទាំង ៧ រូបភ្នំទាំង ៧ រូបស្រះទឹកទាំង ៧ រូបស្តេចគ្រុឌ រូបក្រពើ រូបទង់ជ័យ និងរូបទង់សំពត់ រូបវហ៍កែវ (គ្រែស្នែង) រូបផ្ចិតមាស រូបភ្នំកៃលាស រូបស្តេចរាជសីហ៍ រូបស្តេចខ្លាធំ រូបស្តេចសេះវលាហកៈ រូបស្តេចដំរីឧបោសថ និងរូបស្តេចដំរីឆទ្ទន្ត ស្តេចនាគវាសុកី រូបស្តេចហង្ស រូបស្តេចគោឧសភ រូបស្តេចដំរីឯរាវ័ណ រូបមករមាស (ដូចនាគ តែមានជើង) រូបសំពៅមាសមុខបួន រូបមេគោដោះ រូបកិន្នរ រូបកិន្នរី រូបសត្វករវិក រូបសត្វស្តេចក្ងោក រូបសត្វស្តេចក្រៀល រូបស្តេចសត្វចាក្រពាក រូបស្តេចសត្វព្រហីត[១] (សត្វជីវញ្ជីវ) រូបទេវលោក ៦ ជាន់ និងរូបព្រហ្ម ១៦ ជាន់ ។ ដោយប្រការ

១ ដីកាប្រាប់ថា សត្វនេះមានរូបធំ ប្រមាណប៉ុនសត្វក្ងោក មានស្លាបដ៏វិចិត្រ មាននៅក្នុងដែនទក្ខិណាបថជាដើម ។

*ដូច្នេះ មង្គល ១០៨ នឹងកើតឡើង ការមានបរិវារជាច្រើន ជាអានិសង្សនៃការឲ្យទាន ព្រមដោយបរិវារនោះ ។*

*សេចក្តីក្នុងគម្ពីរជិនាលង្ការដីកា មានដូច្នេះគឺ*

**ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានី**តិ ចក្កលក្ខណំ នាម ទ្វីសុ បាទតលេសុ ទ្វេ ចក្កានិ ។ ឯកេកស្មឹ សហស្សមត្តា អរា យុត្តា ហោន្តិ ។ នេមិវលយំ សុវណ្ណវណ្ណំ ។ នាភិ ឥន្ទនីលមណិវណ្ណា ។ តស្មឹ មជ្ឈេ ច នាភិបរិយន្តេ ច នាភិមុខេ ច វដ្ដលេខា ។ មជ្ឈេ ឆិទ្ទំ ។ ចក្កបរិយន្តេ នេមិតោ ពហិទ្ធា វដ្ដេ សត្តិ, សិរិវច្ឆោ, នន្ទិយាវដ្ដំ, សោវត្ថិកោ, វដំសកំ, វឌ្ឍមានកំ, ភទ្ទបីឋំ, អង្កុសោ, បាសាទំ, តោរណំ, សេតច្ឆត្តំ, ខគ្គំ, តាលវណ្ដំ, មយូរហត្ថំ, ចាមរំ, ឧណ្ហីសំ, បត្តំ, មណិ, សុមនទាមំ, នីលុប្បលំ, រត្តុប្បលំ, រត្តបទុមំ, សេតបទុមំ, បុណ្ឌរីកំ, បុណ្ណកលសំ, បុណ្ណបត្តំ, សមុទ្ទោ, ចក្កវាឡបព្វតោ, ហិមវន្តបព្វតោ, មេរុបព្វតោ, សុរិយមណ្ឌលំ, ចន្ទមណ្ឌលំ, នក្ខត្តំ, សបរិវារា ចតុមហាទីបា, សត្តរតនសមង្គីចក្កវត្តិ, ទក្ខិណាវត្តសេតសង្ខំ, សុវណ្ណមច្ឆយុគឡំ, ចក្កាវុធំ, សត្ត មហាគង្គា, សត្ត កុលបព្វតា, សត្ត សីទន្តសាគរា,

សុបណ្ណរាជា, សុសុមារោ, ធជបតាកា, សុវណ្ណសិវិកា, សុវណ្ណវាល-ពីជនី, កេលាសបព្វតោ, សីហរាជា, ព្យគ្ឃរាជា, វលាហកអស្សរាជា, ឧបោសថឆទ្ទន្តហត្ថិរាជា, វាសុកីនាគរាជា, ហំសរាជា, ឧសភរាជា, ឯរាវណហត្ថិរាជា, សុវណ្ណមករំ, ចតុមុខសុវណ្ណនាវា, សវច្ឆកាធេនុ, កឹបុរិសោ, កិន្នរី, ករវីកោ, មយូររាជា, កោញ្ចរាជា, ចក្កវាករាជា, ជីវញ្ជីវករាជា, ឆ ទេវលោកា, សោឡស ព្រហ្មលោកាតិ ឥមេ ឯត្តកា អគ្គមង្គលលក្ខណា បាទតលេ បញ្ញាយន្តិ ។

*ពាក្យថា* **ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** *សេចក្តីថា ដែលឈ្មោះថា ចក្កលក្ខណៈ ជាកងចក្រពីរខាងក្នុងព្រះបាទទាំងពីរ ។ កាំមានប្រមាណមួយពាន់ក្នុងកងចក្រម្ខាងៗ ។ ស្នាមកង់មានពណ៌មាស ។ ដុំមានពណ៌ដូចកែវឥន្ទនីល ។ មានស្នាមមូលក្នុងកណ្តាលកងចក្រ គម្របដុំ និងមាត់ដុំ ។ មានផ្លុះចំកណ្តាល ។ ក្នុងខាងក្រៅដុំ ជាទីបំផុតរបស់កងចក្រមានសញ្ញលក្ខណៈរបស់មង្គលដ៏ស្អាតក្រៃលែងគឺ រូបលំពែង, រូបផ្ទះកំពូល, រូបផ្កាចន្ទ, រូបសវត្ថិកៈ, រូបផ្កាឈើក្រងលើសីសៈ, រូបថាសដាក់គ្រឿងសំណែន រូបតាំងមាស, រូបកង្វេរ, រូបប្រាសាទ, រូបបង្គោលរបង, រូបស្វេតច្ឆត្រ, រូបព្រះខ័ន, រូបផ្លិតស្លឹកត្នោត, រូបផ្លិតកន្ទុយក្ងោក, រូបផ្លិតកន្ទុយក្ងោក, រូបក្បាំង, រូបបាត្រ, រូបកែវមណី, រូបភួងផ្កាម្លិះ, រូបព្រលឹតខៀវ, រូបព្រលឹត*

ក្រហម, រូបផ្កាបទុមក្រហម, រូបផ្កាបទុមស, រូបផ្កាបុណ្ឌរិក, រូបផ្កា-បុណ្ឌរិកស, រូបធ្នាំងដាក់ទឹកពេញ, រូបថាសដាក់ទឹកពេញ, រូបមហាសមុទ្រ, រូបភ្នំចក្កវាឡ, រូបភ្នំហេមពាន្ត, រូបភ្នំសិនេរុ, រូបព្រះអាទិត្យ, រូបព្រះច័ន្ទ, រូបផ្កាយនក្ខត្តឫក្ស, រូបទ្វីបធំទាំង ៤ និងរូបទ្វីបតូចៗ, រូបព្រះចៅចក្រពត្តិ និងរូបបរិវារ, រូបសង្ខសវិលទៅខាងស្តាំ, រូបត្រីមាសមួយគូ, រូបកងចក្រ, រូបស្ទឹងធំ ៧ ខ្សែ, រូបភ្នំសីទន្តរ ៧ កន្លែង, រូបស្តេចគ្រុឌ, រូបក្រពើ, រូបទង់ជ័យ និងរូបទង់សំពត់, រូបវហ៍មាស, រូបវាលវីជនីមាស, រូបភ្នំកៃលាស, រូបស្តេចរាជសីហ៍, រូបស្តេចខ្លាធំ, រូបស្តេចសេះវលាហកៈ, រូបស្តេចដំរីឧបោសថ និងស្តេចដំរីឆទ្ទន្ត, រូបស្តេចនាគវាសុកី, រូបស្តេចហង្ស, រូបស្តេចគោឧសភ, រូបស្តេចដំរីឯរាវ័ណ, រូបមករមាស, រូបសំពៅមាសមុខបួន, រូបមេគោជោះ, រូបកិន្នរ, រូបកិន្នរី, រូបសត្វករវិក, រូបស្តេចក្ងោក, រូបស្តេចក្រៀល, រូបស្តេចសត្វចាក្រពាក, រូបស្តេចសត្វព្រហីត[1] (សត្វជីវញ្ជីវ), រូបទេវលោក ៦ ជាន់ និងព្រហ្មលោក ១៦ ជាន់ ដូច្នេះ ។

---

១ ដីកាប្រាប់ថា សត្វនេះមានរូបធំ ប្រមាណប៉ុនសត្វក្ងោក មានសម្លាបដ៏វិចិត្រ មាននៅក្នុងដែនទក្ខិណាបថជាដើម ។

## រូបមង្គល ១០៨

១.រូបលំពែង

២.រូបផ្ទះកំពូល

៣.រូបផ្កាចន្ទ

៤ រូបសវត្ថិកៈ គឺរូបស្នាមកាកបាទទាញទៅមុមខាងស្តាំ

៥.រូបផ្កាឈើក្រងលើសីសៈ

៦.រូបថាសដាក់គ្រឿងសំណែន

៧.រូបតាំងមាស

៨.រូបកន្ទេរដ៏រី

៩.រូបប្រាសាទ

១០.រូបសសរបង្គោល

១១.រូបស្វេតច្ឆត្រ

១២.រូបព្រះខ័ន

១៣.រូបផ្ចិតស្លឹកត្នោត

១៤.រូបផ្ចិតកន្ទុយក្ងោក

១៥.រូបក្បាំង

១៦.រូបបាត្រ

១៧.រូបកែវមណី

១៨.រូបក្អងផ្កាម្លិះ

១៩.រូបព្រលឹតខៀវ

២០.រូបព្រលឹតក្រហម

២១.រូបព្រលឹតស

២២.រូបផ្កាឈូកក្រហម

២៣.រូបផ្កាឈូកស

២៤.រូបឆ្នាំងដាក់ទឹកពេញ

២៥.រូបថាសដាក់ទឹកពេញ

២៦.រូបមហាសមុទ្រ

២៧.រូបភ្នំចក្កវាឡ

២៨.រូបភ្នំហេមពាន្ត តាំងនៅក្នុងជម្ពូទ្វីប

២៩.រូបភ្នំសិនេរុ

៣០.រូបព្រះអាទិត្យ

៣១.រូបព្រះចន្ទ

៣២.រូបផ្កាយនក្ខត្តឫក្ស

៣៣.រូបជម្ពូទ្វីប

៣៤.រូបបុព្វវិទេហទ្វីប

៣៥.រូបអបរគោយានទ្វីប

៣៦.រូបឧត្តរកុរុទ្វីប

៣៧.រូបព្រះចៅចក្រពត្តិ និងរូបបរិវារ

៣៨.រូបស័ង្ខសវិលទៅខាងស្តាំ

៣៩.រូបត្រីមាសមួយគូ

៤០.រូបកង់ចក្រ

៤១.រូបស៊ីងធំ ទី ១

៤២. រូបស៊ីងធំ ទី ២

៤៣. រូបស៊ីងធំ ទី ៣

៤៤. រូបស៊ីងធំ ទី ៤

៤៥. រូបស៊ីងធំ ទី ៥

៤៦. រូបស៊ីងធំ ទី ៦

៤៧. រូបស៊ីងធំ ទី ៧

៤៨.រូបភ្នំយុគន្ធរ

៤៩.រូបភ្នំឥសិន្ធរ:

៥០.រូបភ្នំករវិក

៥១.រូបភ្នំសុទស្សនៈ

៥២.រូបភ្នំនេមិន្ធរ:

៥៣.រូបភ្នំវិន្តកៈ

៥៤.រូបភ្នំអស្សកណ្ណ:

៥៥.រូបស្រះអនោតត្តៈ

៥៦.រូបស្រះកណ្ណមុណ្ឌៈ

៥៧.រូបស្រះរថការៈ

៥៨.រូបស្រះឆទ្ទន្តៈ

៥៩.រូបស្រះកុណាលៈ

៦០.រូបស្រះមណ្ឌាកិនី

៦១.រូបស្រះសីហប្បបាត:

៦២.រូបស្ដេចគ្រុឌ

៦៣.រូបក្រពើ

៦៤.រូបទង់ជ័យ

៦៥.រូបទង់សំពត់

៦៦.រូបវហ៍កែវ (ក្រៃស្នេង)

៦៨.រូបក្អំកៃលាស

៦៩.រូបស្ដេចរាជសីហ៍

៧០.រូបស្ដេចខ្លាធំ

៧១.រូបស្ដេចសេះវលាហក:

៧២.រូបស្ដេចដំរីឧបោសថ

៧៣.រូបស្ដេចនាគវាសុកី

៧៤.រូបស្ដេចហង្ស

៧៥.រូបស្ដេចគោឧសភ

៧៦.រូបស្ដេចដំរីឯរាវ័ណ

៧៧.រូបមករមាស (ដូចនាគ តែមានជើង)

៧៨.រូបសំពៅមាសមុខបួន

៧៩.រូបមេគោជោះ

៨០.រូបកិន្នរ

៨១.រូបកិន្នរី

៨២.រូបសត្វករវិក

៨៣.រូបស្តេចក្អែក

៨៤.រូបស្តេចក្រៀល

៨៥.រូបស្តេចសត្វចាក្រពាក

៨៦.រូបស្តេចសត្វព្រហីត[១] (សត្វជីវញ្ជីវ)

៨៧.រូបស្ថានសួគ៌ជាន់ចាតុម្មហារាជិកា

៨៨.រូបស្ថានសួគ៌ជាន់តាវត្តិង្ស

៨៩. រូបស្ថានសួគ៌ជាន់យាមា

៩០. រូបស្ថានសួគ៌ជាន់តុសិត

៩១. រូបស្ថានសួគ៌ជាន់និម្មានរតី

៩២. រូបស្ថានសួគ៌ជាន់បរនិម្មិតវសវតី

៩៣.រូបស្ថានព្រហ្មលោកជាន់បារិសជ្ជា

៩៤.រូបស្ថានព្រហ្មលោកជាន់បុរោហិតា

៩៥. រូបស្ថានព្រហ្មលោកជាន់មហាព្រហ្មា

៩៦. រូបស្ថានព្រហ្មលោកជាន់បរិត្តាភា

៩៧. រូបស្ថានព្រហ្មលោកជាន់អប្បមាណាភា

៩៨. រូបស្ថានព្រហ្មលោកជាន់អាភស្សរា

---

១ ដីកាប្រាប់ថា សត្វនេះមានរូបធំ ប្រមាណប៉ុនសត្វក្អែក មានសម្លាបដ៏វិចិត្រ មាននៅក្នុងដែនទក្ខិណាបថជាដើម ។

៩៩. រូបស្ថានព្រហ្មលោកជាន់បរិត្តសុភា

១០០. រូបស្ថានព្រហ្មលោកជាន់អប្បមាណសុភា

១០១. រូបស្ថានព្រហ្មលោកជាន់សុភកិណ្ហា

១០២. រូបស្ថានព្រហ្មលោកជាន់វេហប្ផលា

១០៣. រូបស្ថានព្រហ្មលោកជាន់អសញ្ញសត្ត

១០៤.រូបស្ថានព្រហ្មលោកជាន់អវិហា

១០៥.រូបស្ថានព្រហ្មលោកជាន់អតប្បា

១០៦.រូបស្ថានព្រហ្មលោកជាន់សុទស្សា

១០៧.រូបស្ថានព្រហ្មលោកជាន់សុទស្សី

១០៨. រូបស្ថានព្រហ្មលោកជាន់អកនិដ្ឋ

## មង្គល ១០៨ និងអត្ថន័យ

១ រូបលំពែង (សត្តិ) លំពែងជាអាវុធសម្រាប់ប្រើក្នុងសង្គ្រាម សម្រាប់ព្រះមហាក្សត្រ មានអត្ថន័យថា អំណាចផ្លូវលោក ។

២ រូបផ្ទះកំពូល (សិរិវច្ឆោ) ផ្ទះដែលលើកហោជាងយ៉ាងស្អាត មានអត្ថន័យថា សិរីមង្គល ។

៣ រូបផ្កាចន្ទ (នន្ទិយាវដ្តំ) មានអត្ថន័យថា សិរីមង្គល ។

៤ រូបសវត្ថិកៈ (សោវត្ថិកំ) ស្នាមកាកបាទចុងបាក់មុមស្ដាំ សេចក្ដីថា ការវិលរបស់កាលវេលា មានអត្ថន័យថា តាំងនៅមាំទាំ ។

៥ រូបផ្កាឈើក្រងលើសីស: (វជំសកំ) ជាគ្រឿងទ្រទ្រង់សម្រាប់ព្រះមហាក្សត្រ មានអត្ថន័យថា យសសក្តិ ។

៦ រូបថាសដាក់គ្រឿងសំណែន (វឌ្ឍមានំ) មានអត្ថន័យថា សិរីមង្គល ការសម្បូណ៌រុងរឿង ព្រោះថាសដាក់គ្រឿងសំណែនសម្រាប់ពិធីបួងសួង ។

៧ រូបតាំងមាស (កទ្ទុបីឋំ) តាំងមាសជាទីប្រថាប់របស់ព្រះមហាក្សត្រ មានអត្ថន័យថា យសសក្តិ និងអំណាចខ្ពង់ខ្ពស់ ។

៨ រូបកង្វេរ (អង្កុសោ) កង្វេរដំរីជាគ្រឿងសម្គាល់ប្រចាំតំណែងព្រះមហាក្សត្រ ព្រោះក្សត្រនៅក្នុងសម័យបុរាណត្រូវរៀនជិះដំរីជំនាញជំរី បង្ហាប់ដំរីដើម្បីធ្វើសង្គ្រាម មានអត្ថន័យថា អំណាច និងយសក្តិដ៏ខ្ពង់ខ្ពស់ ។

៩ រូបប្រាសាទ (បាសាទោ) ប្រាសាទជាទីប្រថាប់របស់ព្រះមហាក្សត្រ មានអត្ថន័យថា យសសក្តិ និងអំណាចដ៏ខ្ពង់ខ្ពស់ ។

១០ រូបសសរបង្គោល (តោរណំ) មានអត្ថន័យថា សភាពមាំទាំ ។

១១ រូបស្វេតច្ឆត្រ (សេតច្ឆត្តំ) ជាគ្រឿងបញ្ជាក់ដល់ព្រះមហាក្សត្រ មានអត្ថន័យថា យសសក្តិ និងអំណាច ។

១២ រូបព្រះខ័ន (ខគ្គំ) ជាអាវុធប្រចាំអង្គព្រះមហាក្សត្រ មានអត្ថន័យ ថា យសសក្តិ និងអំណាច ។

១៣ រូបផ្លិតស្លឹកត្នោត (តាលវណ្តំ) ជាគ្រឿងប្រើរបស់ព្រះភិក្ខុ ជាគ្រឿងបញ្ជាក់ភាពល្អ មានអត្ថន័យថា សិរីមង្គល ។

១៤ រូបផ្ចិតកន្ទុយក្ងោក (មោរហត្ថំ) ជាគ្រឿងប្រកបឥស្សរិយយស របស់ក្សត្រ មានអត្ថន័យថា យសសក្តិ ។

១៥ រូបក្បាំង (ខណ្ឌិសំ) ជាគ្រឿងរាជកកុធភណ្ឌ ដែលជាគ្រឿងសម្តែងដល់ភាពជាក្សត្រ មានអត្ថន័យថា យសសក្តិ និងអំណាចខ្ពង់ខ្ពស់ (រាជកកុធភណ្ឌ ៥ គឺ ព្រះខ័ន ស្វេតច្ឆត្រ ក្បាំង ទ្រនាប់ជើងមាស និងផ្ចិតកន្ទុយចាមរី ) ។

១៦ រូបបាត្រ (បត្តំ) ជាគ្រឿងបរិក្ខាររបស់ព្រះភិក្ខុ មានអត្ថន័យថា សិរីមង្គល ។

១៧ រូបកែវមណី (មណិ) មានអត្ថន័យថា សភាពមាំទាំ ។

១៨ រូបក្លងផ្កាម្លិះ (សុមនទាមំ) មានអត្ថន័យថា សិរីមង្គល ព្រោះផ្កាម្លិះជាផ្កាមានក្លិនក្រអូបជាងផ្កាដទៃ ។

១៩ រូបផ្កាព្រលឹតខៀវ (នីលុប្បលំ) ផ្កាព្រលឹតជាសញ្ញលក្ខណៈរបស់ទឹក មានអត្ថន័យថា ការសម្បូរសប្បាយ ការរុងរឿង និងភាពបរិសុទ្ធ។

២០ រូបព្រលឹតក្រហម (រត្តុប្បលំ) អត្ថន័យ ដូចខទី ១៩

២១ រូបព្រលឹតស (សេតុប្បលំ) អត្ថន័យ ដូចខទី ១៩

២២ រូបផ្កាឈូកក្រហម (បទុមំ) អត្ថន័យ ដូចខទី ១៩

២៣ រូបផ្កាឈូកស (បុណ្ឌរីកំ) អត្ថន័យ ដូចខទី ១៩

២ រូបឆ្នាំងដាក់ទឹកពេញ (បុណ្ណឃដោ) មានអត្ថន័យថា ការសម្បូរការចម្រើន និងជោគល្អ

២៥ រូបថាសដាក់ទឹកពេញ (បុណ្ណបាតិ) មានអត្ថន័យដូចខទី ២៤ ។

២៦ រូបសមុទ្រ (សមុទ្ទា) សំដៅដល់ មហាសមុទ្រទាំង ៤ បានដល់

ក.នីលសាគរ មហាសមុទ្រពណ៌ខៀវ ស្ថិតនៅទិសខាងត្បូងរបស់ភ្នំសិនេរុ មានពណ៌ដូចកែវឥន្ទនីល

ខ.ខីរសាគរ មហាសមុទ្រពណ៌ស ស្ថិតនៅទិសខាងកើតរបស់ភ្នំសិនេរុ ដែលមានពណ៌ប្រាក់

គ បីតសាគរ មហាសមុទ្រពណ៌លឿង ស្ថិតនៅទិសខាងជើងភ្នំសិនេរុ ដែលមានពណ៌មាស

ឃ.ផលិកសាគរ មហាសមុទ្រមានពណ៌កែវផលិក ស្ថិតនៅទិសខាងលិចរបស់ភ្នំសិនេរុ ដែលមានពណ៌ដូចកែវផលិក ហៅមួយទៀតថាបកតិសាគរ គឺមហាសមុទ្រតាមប្រក្រតី

២៧ រូបភ្នំចក្កវាឡ (ចក្កវាឡំ) គឺ ភ្នំដែលជាទីតាំងរបស់ចក្កវាឡលិចចុះក្នុងមហាសមុទ្រទាំង ៤ ។ ភ្នំចក្កវាឡនេះខ្ពស់ផុតពីទឹក ៨២,០០០ យោជន៍ និងមុជចុះនៅក្រោមទឹក ៨២,០០០ យោជន៍ ។

២៨ រូបភ្នំហេមពាន្ត (ហិមវា) តាំងនៅក្នុងជម្ពូទ្វីប

២៩ រូបភ្នំសិនេរុ (មេរុ) ជាផ្ចិតគោលរបស់ចក្កវាឡ តាមសេចក្តីជឿក្នុងព្រះពុទ្ធសាសនា មានកម្ពស់ កម្រាស់ និងលិចចុះទៅខាងក្រោម ៨៤,០០០ យោជន៍ ។ ចំណែកកំពូលជាទីតាំងរបស់សួគ៌ជាន់តាវតិង្ស ។

៣០ រូបព្រះអាទិត្យ (សូរិយោ) ជាផ្កាយគោចរជុំវិញភ្នំមេរុ ក្នុងលំដាប់កំពូលភ្នំយុគន្ធរ ដែលទាបជាងភ្នំព្រះសុមេរុ ធ្វើឲ្យកើតរដូវកាលគឺហេមន្តរដូវ (រដូវរងា) ខែ ១២-១-២-៣ ព្រះអាទិត្យគោចរក្នុងគោណវិថី, គិម្ហន្តរដូវ (រដូវក្តៅ) ខែ ៤-៥-៦-៧ ព្រះអាទិត្យគោចរក្នុងអជវិថី, វស្សានរដូវ (រដូវភ្លៀង) ខែ ៨-៩-១០-១១ ព្រះអាទិត្យគោចរក្នុងនាគវិថីៗ

៣១ រូបព្រះចន្ទ (ចន្ទិមា) ជាផ្កាយដែលគោចរជុំវិញភ្នំព្រះសុមេរុ ដូចគ្នា តែមានវង់គោចរទាបជាងព្រះអាទិត្យ ១,០០០ យោជន៍ ។

៣២ រូបផ្កាយនក្ខត្តឫក្ស (នក្ខត្តា) សំដៅដល់ ផ្កាយ ២៧ ពួក គឺ ១.អស្សិនី ២.ភរណី ៣.កឫតិកា ៤.រោហិណី ៥.មឫគសិរ ៦.អាទ្រា ៧.បុនព្វសុ ៨.បុស្ស: ៩.អាសលេសា ១០.មឃា ១១.បុព្វផល្គុនី ១២.ឧត្តរផល្គុនី ១៣.ហស្ត: ១៤.ចិត្រ: ១៥.សវាតិ ១៦.វិសាខា ១៧.អនុរាធ ១៨.ជេដ្ឋា ១៩.មូល: ២០.បុព្វសាឍ ២១.ឧត្តរសាឍ ២២.សវរណ: ២៣.ធនិដ្ឋ: ២៤.សតភិសជ ២៥.បុព្វភទ្របទ ២៦.ឧត្តរ-ភទ្របទ ២៧.រេវតី ។

៣៣-៣៦ រូបទ្វីបធំទាំង ៤ និងរូបទ្វីបតូច (ចតុរោ មហាទីបា បរិត្ត-ទីបា) គឺ ទ្វីបធំទាំង ៤ ដែលជាដែនកើតរបស់មនុស្ស និងទ្វីបតូចដែលជុំវិញ ជាបរិវាររបស់ទ្វីបទាំង ៤ ។ ទ្វីបធំទាំង ៤ មានទ្វីបជាបរិវារ ៥០០ៗ ទ្វីប មានសញ្ញាលក្ខណ:ជាដើមឈើតាំងនៅរហូតកប្ប ។ ទ្វីបធំទាំង ៤ នោះ តាំងនៅទាំង ៤ ផ្នែក របស់ភ្នំព្រះសុមេរ បានដល់

ក.ជម្ពូទ្វីប នៅទិសខាងត្បូង មានដើមព្រីងជាសញ្ញាលក្ខណៈ ជាទ្វីបដែលមនុស្សយើងនៅអាស្រ័យ ជាស្ថានទីកើតឡើងនៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ពុទ្ធសាវ័ក និងស្តេចចក្រពត្តិ មានសណ្ឋានជារូបរទេះ ទទឹង ១០,០០០ យោជន៍ ប៉ុនស្ថានសួគ៌ជាន់តាវតិង្ស ក្រុងអសុរ និងអវចីនរក មនុស្សដែលអាស្រ័យនៅមានមុខដូចរូបរទេះ ។

ខ.បុព្វវិទេហទ្វីប ស្ថិតនៅខាងកើត មានដើមផ្ទីកជាសញ្ញាលក្ខណៈ មានសណ្ឋានដូចព្រះចន្ទខាងរនោច ទទឹង ៧,០០០ យោជន៍ មនុស្សមានមុខដូចព្រះចន្ទខាងរនោច ។

គ.អបរគោយានទ្វីប ស្ថិតនៅទិសខាងលិច មានដើមក្តុម្ព ជាសញ្ញាលក្ខណៈ មានសណ្ឋានដូចកញ្ចក់ ទទឹង ៧,០០០ យោជន៍ មនុស្សមានមុខដូចរូបកញ្ចក់ ។

ឃ.ឧត្តរកុរុទ្វីប ស្ថិតនៅទិសខាងជើង មានដើមកល្បព្រឹក្ស ជាសញ្ញាលក្ខណៈ មានសណ្ឋានបួនជ្រុងដូចតាំង ទទឹង ៨,០០០ យោជន៍ មនុស្សមានមុខដូចបួនជ្រុង ទទឹងនិងបណ្តោយប៉ុនគ្នា ជាដែនកើតរបស់មនុស្សបំពេញកុសលទុកច្រើន ពោលគឺ មនុស្សគ្រប់គ្នា មានមុខមាត់រូបរាងស្អាតៗ ។ បុរសមានវ័យដូចមនុស្សអាយុ ២៥ ឆ្នាំ ។ ស្ត្រីមានវ័យដូចមនុស្សអាយុ ១៦ ឆ្នាំ តាំងពីចម្រើនវ័យ រហូដល់ស្លាប់ទៅវិញ ។ មិនមានភ័យអំពីធម្មជាតិ ឬសត្វសាហាវ ។ មានអាហារ និងគ្រឿងដណ្តប់កើតអំពីបុណ្យ ដោយមិនត្រូវធ្វើការងារ មានរដូវកាល ជាទីសប្បាយ

មិនក្តៅ មិនត្រជាក់ ។ កាលមនុស្សទាំងនោះស្លាប់ទៅហើយ រមែងទៅកើតក្នុងស្ថានតាវតិង្ស ព្រោះជាអ្នករក្សានិច្ចសីល ជាប់ជានិច្ច ។

៣៧ រូបព្រះចៅចក្រពត្តិ និងបរិវារ (សបរិសោ ចក្កវត្តិ) ព្រះចៅចក្រពត្តិ គឺ រាជារបស់ក្សត្រទូទាំងពិភពលោក មានកំណើតនៅក្នុងជម្ពូទ្វីប តាមការជឿក្នុងព្រះពុទ្ធសាសនាថា ក្នុងរវាងដែលមិនមានព្រះពុទ្ធត្រាស់ដឹងក្នុងលោក គ្រាខ្លះមានព្រះចៅចក្រពត្តិគ្រប់គ្រងទ្វីប ប្រកបដោយគុណធម៌ និងចរិយាធម៌ ជាអ្នកមានទ្រព្យសម្បត្តិច្រើន និងបរិវារច្រើន ។

៣៨ រូបសង្ខសវិលទៅខាងស្តាំ (ទក្ខិណាវត្តសេតសង្ខោ) គឺសង្ខសមានលក្ខណៈវិលទៅស្តាំ ។ សង្ខជាសញ្ញាលក្ខណៈរបស់ពិធីព្រាហ្មណ៍ផ្សេងៗ មានអត្ថន័យថា សិរីមង្គល ។

៣៩ រូបត្រីមាសគូ (សុវណ្ណមច្ឆយុគលំ) ជាសញ្ញាលក្ខណៈរបស់ទឹក និងជីវិត មានអត្ថន័យថា ការសម្បូរ សេចក្តីចម្រើន

៤០ រូបកងចក្រ (ចក្កំ) ជាគ្រឿងសម្គាល់នៃការកម្ចាត់សត្រូវ មានអត្ថន័យថា ជ័យជម្នះ ។

៤១-៤៧ រូបទឹកស្ទឹង ៧ ខ្សែ (សត្ត មហាគង្គា) គឺ ស្ទឹងសីទន្តរទាំង ៧ ដែលនៅរវាងភ្នំសត្តបរិកណ្ឌ ដែលឡោមពទ្ធជុំវិញភ្នំព្រះសុមេរុ ។ កន្លែងខ្លះហៅថា សីទា ប្រែថា ស្ទឹងលិចទូក ព្រោះមានទឹកល្អិតសុខុម រហូតមិនមានវត្ថុណាមួយ អាចស្ថិតនៅលើទឹកនោះបានឡើយ ដោយហោចទៅសូម្បីតែរោមកន្ទុយក្ងោក ។

៤៨-៥៤ រូបរណ្តៅភ្នំ ៧ (សត្ត មហាសេលា) គឺ ភ្នំសត្តបរិភណ្ឌ ៧ ដែលឡោមពទ្ធភ្នំព្រះសុមេរុ បានដល់

ក.ភ្នំយុគន្ធរ

ខ.ភ្នំឥសិន្ធរ

គ.ភ្នំករវិក

ឃ.ភ្នំសុទស្សនៈ

ង.ភ្នំនេមិន្ធរ

ច.ភ្នំវិន្តកៈ

ឆ.ភ្នំអស្សកណ្ណៈ

លំដាប់ភ្នំទាំង ៧ នេះ ពោលតាមគម្ពីរវិសុទ្ធិមគ្គ និងសមន្តប្បាសា-ទិកា ។ តែក្នុងនិមិជាតក និងជួបលំដាប់ផ្តើមអំពីភ្នំសុទស្សនៈ ភ្នំករវិក ភ្នំឥសិន្ធរ ភ្នំយុគន្ធរ ភ្នំនេមិន្ធរ ភ្នំវិន្តកៈ និងភ្នំអស្សកណ្ណៈ ។ គម្ពីរជិនាលង្ការដីកា អធិប្បាយរឿងនេះថា ព្រះបាទនេមិរាជត្រាស់សួរភ្នំសត្តបរិភណ្ឌ ក្នុងខណៈដែលមកដល់ភ្នំសុទស្សនៈហើយ ។ មាតលិទេវបុត្រទើបពោលថា ភ្នំផ្តើមតាំងតែភ្នំសុទស្សនៈ ដែលនៅត្រង់ចំពោះមុខ ហើយរាប់បែបបដិ-លោមន័យ បន្ទាប់មកទើបរាប់ឈ្មោះភ្នំដែលកន្លងមកហើយ តាមបែបអនុលោមន័យ ។

៥៥-៦១ រូបស្រះធំ ៧ កន្លែង (សត្ត មហាសរា) គឺ ស្រះធំទាំង ៧ ក្នុងព្រៃហេមពាន្ត បានដល់

ក.អនោតត្តស្រះ

ខ.កណ្ណមុណ្ឌស្រះ

គ.រថការស្រះ

ឃ.ឆទ្ទន្តស្រះ

ង.កុណាលស្រះ

ច.មណ្ឌាកិនីស្រះ

ឆ.សីហប្បបាតស្រះ

៦២ រូបស្តេចគ្រុឌ (សុបណ្ណរាជា) គ្រុឌជាសត្វដែលមានឫទ្ធិច្រើន មានលក្ខណៈជាមនុស្សផ្សំនឹងសត្វ មានកាយធំ កម្ពស់ជាង ៥០ យោជន៍ មានទីនៅដូចជាទេវតា អាស្រ័យនៅក្នុងបរិវេណព្រៃរកា ជុំវិញស្រះសិម្ពលី ក្នុងព្រៃហេមពាន្ត ។ ក្នុងគតិព្រាហ្មណ៍ សត្វគ្រុឌ ជាពាហនៈរបស់ព្រះនារាយណ៍ ។

៦៣ រូបក្រពើ (សុសុមារកោ) ក្រពើជាសញ្ញលក្ខណៈរបស់ទឹកសំដៅដល់ ការសម្បូរ ។

៦៤ រូបទង់ជ័យ (ធជោ) មានអត្ថន័យថា យសសក្តិ អំណាច និងជ័យជម្នះ ។

៦៥ ទង់សំពត់ (បដាកំ) មានអត្ថន័យថា កិត្តិយស ។

៦៦ រូបវល្លិ៍កែវ (រតនបាដង្គី) ជាទីប្រថាប់របស់ព្រះមហាក្សត្រ មានអត្ថន័យថា យសសក្តិ និងអំណាច ។

៦៧ រូបផ្លិតមាស (សុវណ្ណវាលវីជនី) ជាគ្រឿងប្រើប្រាស់ខ្ពស់របស់ព្រះមហាក្សត្រ មានអត្ថន័យថា អំណាច និងយសសក្តិ ។

៦៨ រូបភ្នំកៃលាស (កេលាសបព្វតោ) តាំងនៅក្នុងញកភ្នំហេមាល័យ។ ក្នុងគតិរបស់ព្រាហ្មណ៍ជាភ្នំទីមរបស់ចក្កវាឡ ជាទីប្រថាប់របស់ព្រះឥស្វរ។ មានអត្ថន័យថា បារមីរបស់ព្រះពុទ្ធជាម្ចាស់ មាននៅលើពួកទេពដ៏ខ្ពង់ខ្ពស់បំផុតក្នុងសាសនាព្រាហ្មណ៍ ។

៦៩ រូបស្ដេចរាជសីហ៍ (សីហរាជា) ជាសញ្ញលក្ខណៈសម្ដែងដល់អំណាចរបស់កេសររាជសីហ៍ ដែលអាស្រ័យនៅក្នុងព្រៃហេមពាន្ត មាន ២ ប្រភេទ គឺ មួយពួកមានមាត់ ស្បែក និងជើងទាំង ៤ ពណ៌ក្រហម មួយពួកទៀត មានពណ៌សទាំងកាយ ស៊ីម្រឹគជាអាហារ អាស្រ័យនៅក្នុងល្អាងមាស និងល្អាងប្រាក់ ។ មានអត្ថន័យថា មានឫទ្ធិច្រើន ។

៧០ រូបស្ដេចខ្លាធំ (ព្យគ្ឃរាជា) ជាសត្វអាស្រ័យនៅក្នុងព្រៃហេមពាន្ត ។ មានអត្ថន័យ ដូចខទី ៦៩ ។

៧១ រូបស្ដេចសេះវលាហកៈ (វលាហកោ អស្សរាជា) ជាសេះក្នុងត្រកូលសេះកែវ កើតក្នុងព្រៃហេមពាន្ត លក្ខណៈមានពណ៌ដូចមេឃ មានថ្ងាសនិងក្រចកជើងទាំង ៤ មានពណ៌ដូចទឹកលក្ត ស្បែកស រោមខ្មៅទន់ មានឫទ្ធិអាចហោះបាន ។ ជាសេះគូបារមីព្រះចៅចក្រពត្តិ ។

៧២ រូបស្ដេចដំរីឧបោសថ (ឧបោសថវារណរាជា) ត្រកូលដំរីឧបោសថជាប្រភេទដំរីមួយ ក្នុងដំរីកែវទាំង ១០ ដែលកើតក្នុងព្រៃហេមពាន្ត មានលក្ខណៈពណ៌កាយស ដូចខែពេញបូណ៌មី ជើងនិងភ្នុកមានពណ៌ក្រហម មានឫទ្ធិហោះទៅក្នុងអាកាសបាន ជាដំរីគូបារមីរបស់ស្ដេចចក្រពត្តិ ។

៧៣ រូបស្ដេចនាគវាសុកី (វាសុកី ឧរគរាជា) តាមគតិព្រាហ្មណ៍ថា ជានាគអារុសោ ដែលមានអាយុវែង និងជួយព្រះជាម្ចាស់រឿយៗ ក្នុងការកូរទឹកសមុទ្រជាដើម ។

៧៤ រូបស្ដេចហង្ស (ហំសរាជា) អាស្រ័យនៅក្នុងគុហាមាស លើភ្នំចិត្រកូដ ក្នុងព្រៃហេមពាន្ត ។

៧៥ រូបស្ដេចគោឧសភ (ឧសភរាជា) ជាប្រភេទគោ ស្ថិតនៅក្នុងហ្វូងគោ ដែលមានកម្លាំងច្រើន មានកម្លាំងស្មើនឹងគោដទៃ ៥០០ គោ ។ អាចការពារភ័យអំពីសត្វសាហាវទាំងអស់ ។ មានអត្ថន័យថា ជាសញ្ញលក្ខណៈរបស់សិរី និងការសម្បូរ ។

៧៦ រូបស្ដេចដំរីឯរាវ័ណ (ឯរាវណោ នាគរាជា) ឯរាវណទេវបុត្រនិម្មិតខ្លួនជាដំរី ជាពាហនៈរបស់ព្រះឥន្ទ្រ មានកម្ពស់ ១៥០ យោជន៍ មានក្បាល ៣៣ ហើយក្បាលនីមួយៗ មានភ្លុក ៧ ហើយភ្លុកនីមួយៗ មានស្រះធំៗ ៧ ហើយស្រះនីមួយៗ មានផ្កាឈូក ៧ ហើយផ្កាឈូក ៧ មានត្របក ៧ ហើយត្របកនីមួយ ៗ មាននាងរបាំ ៧ នាក់ ។ កណ្ដាលដំរីឯរាវ័ណ ជាទីប្រថាប់របស់ព្រះឥន្ទ្រ ។

៧៧ រូបមករមាស (សុវណ្ណមករោ) មានអត្ថន័យថា យសសក្តិអំណាច និងជោគល្អ យ៉ាងមាំទាំ ។

៧៨ រូបសំពៅមាសមុខបួន (ចតុមុខា សុវណ្ណនាវា) ជាសម្បត្តិរបស់ព្រះចៅចក្រពត្តិ ។

៧៩ រូបមេគោដោះ (សវច្ឆកា គាវី) មានអត្ថន័យថា ការសម្បូរ ។
៨០ រូបកិន្នរ (កិន្នរោ) ជារូបមនុស្សពាក់កណ្តាល សត្វពាក់កណ្តាល មានខ្លួនជាមនុស្ស ផ្នែកក្រោមជាសត្វ អាស្រ័យនៅលើភ្នំកៃលាស មានក្រុងស្រស់ស្អាត ដូចសួគ៌ជាន់តាវតិង្ស ។ ពាក្យនេះប្រែតាមសព្ទថា អ្នកដែលប្រហែលដូចមនុស្ស ។ តាមគតិព្រាហ្មណ៍ថា មានមុខដូចមនុស្ស ខ្លួនដូចសេះ ឬមានមុខដូចសេះ មានខ្លួនដូចមនុស្ស សោយទិព្វសម្បត្តិ តាមន័យនេះប្រែថា មនុស្សដែលគួរខ្ពើមរអើម។
៨១ រូបកិន្នរី (កិន្នរី) មានលក្ខណៈដូចកិន្នរ តែភេទស្រី ។
៨២ រូបសត្វករវិក (ករវីកោ) ជាសត្វដែលមានសំឡេងពីរោះ អ្នកដែលបានឮសំឡេងរបស់សត្វប្រភេទនេះ រមែងភ្លេចអ្វីដែលកំពុងធ្វើ សំឡេងរបស់សត្វករវិកនេះ ប្រើប្រៀបធៀបសំឡេងរបស់ព្រះព្រហ្ម និងសំឡេងរបស់ព្រះពុទ្ធ ។
៨៣ រូបស្តេចសត្វក្ងោក (មយូររាជា) ជាសញ្ញាលក្ខណៈរបស់ភាពស្រស់ស្អាត និងមានសិរីមង្គល ។
៨៤ រូបស្តេចសត្វក្រៀល (កោញ្ចរាជា) ជាសញ្ញាលក្ខណៈរបស់សិរីមង្គល
៨៥ រូបស្តេចសត្វចាក្រពាក (ចក្កវាករាជា) ជាសញ្ញាលក្ខណៈរបស់សិរីមង្គល
៨៦ រូបស្តេចសត្វព្រហីត (ជីវញ្ជីវករាជា) ជាសញ្ញាលក្ខណៈរបស់សិរីមង្គល

៨៧-៩២ រូបទេវលោក ៦ ជាន់ (ឆ កាមាវចរទេវលោកា) គឺ ស្ថានសួគ៌ ៦ ជាន់ ជាដែនកើតរបស់មនុស្សដែលបានបំពេញបុណ្យកុសល មានទាន សីល ភាវនា ដែលមិនបានទម្លុះឈាន បានដល់

ក.ស្ថានចាតុម្មហារាជិកា

ខ.ស្ថានតាវតិង្ស

គ.ស្ថានយាមា

ឃ.ស្ថានតុសិត

ង.ស្ថាននិម្មានរតី

ច.ស្ថានបរនិម្មិតវសវតី

៩៣-១០៨ រូបព្រហ្មលោក ១៦ ជាន់ (សោឡស ព្រហ្មលោកា) បែងចែកជា ៤ ភូមិ គឺ

ក.បឋមជ្ឈាន មាន ៣ ជាន់ គឺ បារិសជ្ជា បុរោហិតា និងជាន់មហាព្រហ្មា

ខ.ទុតិយជ្ឈាន មាន ៣ ជាន់ គឺ បរិត្តាភា អប្បមាណាភា និងអាភស្សរា

គ.តតិយជ្ឈាន មាន ៣ ជាន់ គឺ បរិត្តសុភា អប្បមាណសុភា និង សុភកិណ្ហា

ឃ.ចតុជ្ឈាន មាន ៣ ជាន់ គឺ វេហប្ផលា ព្រហ្មជាន់អសញ្ញីសត្វ និងព្រហ្មជាន់សុទ្ធាវាស បែងចែកជា ៥ ជាន់ គឺ អវិហា អតប្បា សុទស្សា សុទស្សី និង អកនិដ្ឋា ។

## សរុបសេចក្តីមង្គល ១០៨

រូបមង្គល ១០៨ នេះ ប្រកបដោយរូបមង្គលប្រភេទធំៗ មាន ៥ ក្រុម គឺ

១.ក្រុមសញ្ញលក្ខណៈរបស់ជោគលាភ សេចក្តីចម្រើន និងការសម្បូរ ដូច ផ្ទះកំពូល ផ្កាចន្ទ សវត្ថិកៈ ឆ្នាំងដាក់ទឹកពេញ ថាសដាក់ទឹកពេញ ត្រីគូ កែវមណី ផ្កាឈូក ជាដើម

២.ក្រុមគ្រឿងប្រកបបារមីរបស់ព្រះមហាក្សត្រ និងព្រះចៅចក្រពត្តិ ជាសញ្ញលក្ខណៈរបស់យសសក្តិ អំណាច និងភាពខ្ពង់ខ្ពស់ ដូចផ្កាក្រងលើសីសៈ តាំងមាស កង្វេរ ប្រាសាទ ព្រះខ័ន ផ្លិតកន្ទុយក្ងោក ផ្លិតកន្ទុយចាមរី ជាដើម

៣.ក្រុមបរិក្ខាររបស់ព្រះភិក្ខុ ជាសញ្ញលក្ខណៈរបស់សេចក្តីល្អ និងសិរីមង្គល ដូច បាត្រ ផ្លិតស្លឹកត្នោត

៤.ក្រុមស្តេចសត្វ ជាសញ្ញលក្ខណៈរបស់អំណាច ដូច ស្តេចគ្រុឌ ស្តេចខ្លាធំ ស្តេចសេះវលាហកៈ ស្តេចដំរីឧបោសថ ស្តេចវាសុកី ស្តេចគោឧសភ ស្តេចដំរីឯរាវណ ជាដើម

៥.ក្រុមភពភូមិ ក្នុងចក្កវាឡ មានសេចក្តីជឿក្នុងព្រះពុទ្ធសាសនា ដូច មហាសមុទ្រ ភ្នំចក្កវាឡ ភ្នំហេមពាន្ត ភ្នំសិនេរុ ព្រះអាទិត្យ ព្រះចន្ទ ផ្កាយនក្ខត្តឫក្ស ទ្វីបធំទាំង ៤ ទ្វីបតូច ២,០០០ របួតទៅដល់ទេវលោក ៦ ជាន់ និងព្រហ្មលោក ១៦ ជាន់ ។

## បាទវន្ទនា

បាទេសុ យស្ស ជាតានិ　　ទ្វេ ចក្កានិ សកម្មតោ
នានាការេហិ បុណ្ណានិ　　វន្ទេ តំ បុរិសុត្តមំ ។

*កងចក្កទាំងឡាយពីរ ដែលបរិបូណ៌ដោយលក្ខណៈផ្សេងៗ ប្រាកដ ហើយដោយកម្មរបស់ខ្លួន ក្នុងស្នាមព្រះបាទរបស់ព្រះមហាបុរស អង្គណា ខ្ញុំព្រះករុណាសូមនមស្ការនូវមហាបុរសអង្គនោះ ។*

សត្តិ ច សិរិវច្ឆោ ច　　នន្ទិយាវដ្ដមេវ ច
សោវត្ថិកោ វដំសោ ច　　វឌ្ឍមានញ្ច បីឋកំ ។

*រូបលំពែង រូបផ្ទះកំពូល រូបផ្កាចន្ទ រូបសវត្ថិកៈ រូបផ្កាឈើក្រង លើសីសៈ រូបថាសដាក់គ្រឿងសំណែន រូបតាំងមាស (១-៧) ។*

អង្កុសញ្ចេវ បាសាទោ　　តោរណំ ឆត្តមេវ ច
ខគ្គោ ច តាលវណ្ដញ្ច　　មោរហត្ថកពីជនី ។

*រូបកង្វេរ រូបប្រាសាទ រូបសសរបង្គោល រូបឆត្រ រូបព្រះខ័ន រូបផ្លិតស្លឹកត្នោត រូបផ្លិតកន្ទុយក្ងោក (៨-១៤) ។*

ឧណ្ហីសំ មណិ បត្តញ្ច　　ទាមំ នីលុប្បលំ តថា
រត្តសេតុប្បលញ្ចេវ　　បទុមំ បុណ្ឌរិកំ តថា ។

*រូបក្បាំង រូបកែវមណី រូបបាត្រ រូបកួនផ្កាឈើ រូបព្រលឹតខៀវ រូបព្រលឹតក្រហម រូបព្រលឹតស រូបផ្កាឈូកក្រហម រូបផ្កាឈូកស។* (១៥-២៣)

បុណ្ណឃដោ បុណ្ណបាតិ　　សមុទ្ទោ ចក្កវាឡកំ
ហិមវា សិនេរុ ចេវ　　សុរិយោ ចន្ទិមា តថា ។

*រូបឆ្នាំងដាក់ទឹកពេញ រូបថាសដាក់ទឹកពេញ រូបមហាសមុទ្រ រូបភ្នំចក្កវាឡ រូបភ្នំហេមពាន្ត រូបភ្នំសិនេរុ រូបព្រះអាទិត្យ រូបព្រះចន្ទ ។* (២៤-៣១)

ឆត្តា ចតុរោ ទីឃា　　ទ្វិសហស្សបរិត្តកា
ចក្កវត្តិ សេតសង្ខោ　　មច្ឆានំ យុគឡំ តថា ។

*រូបផ្កាយនក្ខត្តឫក្ស រូបទ្វីបធំទាំង ៤ និងរូបទ្វីបតូច ២,០០០ រូបស្តេចចក្រពត្តិ រូបសង្ខស រូបត្រីគូ* (៣២-៣៩) ។

ចក្កំ សត្ត មហាគង្គា　　មហាសេលា មហាសរា
សុបណ្ណកោ សុសុមារោ　　ធជោ បដាកមេវ ច ។

*រូបកងចក្ក រូបស្ទឹងធំ ៧ ខ្សែ រូបភ្នំទាំង ៧ រូបស្រះធំទាំង ៧ រូបស្តេចគ្រុឌ រូបក្រពើ រូបទង់ជ័យ រូបទង់ជ្រុង* (៤០-៦៥) ។

បាដង្កី វាលវីជនី　　កេលាសបព្វតោ តថា
សីហរាជា ព្យគ្ឃរាជា　　វលាហោ ច ឧបោសថោ។

*រូបវហ៍ រូបផ្ចិតកន្ទុយចាមរី រូបភ្នំកៃលាស រូបស្តេចរាជសីហ៍ រូបស្តេចខ្លាធំ រូបស្តេចសេះវលាហកៈ រូបស្តេចដំរីឧបោសថ (៦៦-៧២) ។*

វាសុកី នាគរាជា ច　　ហំសោ ច ឧសភោ តថា
ឯរាវណោ មករោ ច　　ហរិនាវា ចតុម្មុខា ។

*រូបស្តេចនាគវាសុកី រូបស្តេចហង្ស រូបស្តេចគោឧសភ រូបដំរីឯរាវណ រូបមករ រូបសំពៅមាសមុខបួន (៧៣-៧៨)*

សវច្ឆកា តថា គាវី　　កិន្នរោ កិន្នរីបិ ច
ករវីកោ មយូរោ ច　　កោញ្ចរាជា តថេវ ច ។

*រូបមេគោជោះ រូបកិន្នរ រូបកិន្នរី រូបសត្វករវិក រូបស្តេចសត្វក្ងោក រូបស្តេចសត្វក្រៀល (៧៩-៨៤) ។*

ចក្កវាកទិជោ ចេវ　　ជីវញ្ជីវកនាមកោ
ឆ កាមាវចរា ទេវា　　ព្រហ្មលោកា ច សោឡស ។

*រូបស្តេចសត្វចាក្រពាក រូបស្តេចសត្វព្រហិត រូបទេវលោក ៦ ជាន់ រូបព្រហ្មលោក ១៦ ជាន់ (៨៥-១០៨) ។*

ឯតានដ្ឋុត្តរសតំ　　លក្ខណានិ មហេសិនោ
បាទេសុ យស្ស ទិស្សន្តេ　　វន្ទេ តំ បុរិសុត្តមំ ។

*លក្ខណៈ ១០៨ ទាំងនេះ រមែងប្រាកដក្នុងស្នាមព្រះបាទរបស់ព្រះពុទ្ធអង្គណា ខ្ញុំសូមនមស្ការនូវព្រះពុទ្ធដែលជាបុរសដ៏ឧត្តមអង្គនោះ ។*

## ចាទវន្ទនា ប្រែលោតប្រយោគ

ចក្កានិ រីចក្កទាំងឡាយ ទ្វេ ពីរ ជាតានិ កើតហើយ ចាទេសុ ក្នុងព្រះបាទទាំងឡាយ យស្ស សម្មាសម្ពុទ្ធស្ស នៃព្រះសម្មាសម្ពុទ្ធអង្គណា សកម្មតោ ដោយកម្មរបស់ខ្លួន បុណ្ណានិ ដ៏ពេញ នានាការេហិ ដោយអាការៈផ្សេងៗទាំងឡាយ អហំ រីខ្ញុំព្រះអង្គ វន្ទេ សូមថ្វាយបង្គំ តំ សម្មាសម្ពុទ្ធំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ បុរិសុត្តមំ ដែលជាបុរសឧត្តម ។

មង្គលានិ រីមង្គលទាំងឡាយ អដ្ឋុត្តរសតំ មួយរយប្រាំបី ឥតិ ដូច្នេះ សត្តិ ច គឺលំពែងផង សិរិវច្ឆោ ច គឺផ្ទះកំពូលផង នន្ទិយាវដ្តមេវ ច គឺផ្កាចន្ទួផង សោវត្ថិកោ ច គឺសោវត្ថិកៈផង វដំសោ ច គឺផ្កាឈើក្រងលើសីសៈផង វឌ្ឍមានញ្ច គឺថាសដាក់គ្រឿងសំណែនផង បីឋកំ ច គឺតាំងមាសផង អង្កុសញ្ច គឺកង្វេរផង ចាសាទោ ច គឺប្រាសាទផង តោរណំ ច គឺសសរបង្គោលផង ឆត្តមវ ច គឺឆត្រផង ខគ្គោ គឺព្រះខ័នផង តាលវណ្ដញ្ច គឺផ្លិតស្លឹកត្នោតផង មោរហត្ថកពីជនី ច គឺផ្លិតកន្ទុយក្ងោកផង ឧណ្ហីសំ ច គឺក្បាំងផង មណិ ច គឺកែវមណីផង

បត្តញ្ច គឺបាត្រផង ទាមំ ច គឺភួងផ្កាឈើផង នីលុប្បលំ តថា គឺព្រលិតខៀវផង រត្តសេតុប្បលញ្ច គឺព្រលិតក្រហម និងព្រលិតសផង បទុមំ ច គឺឈូកក្រហមផង បុណ្ឌរិកំ តថា គឺឈូកសផង បុណ្ណឃដោ ច គឺថ្នាំងដាក់ទឹកពេញផង បុណ្ណបាតិ ច គឺថាសពេញដោយទឹកផង សមុទ្ទោ ច គឺសមុទ្រផង ចក្កវាឡកំ ច គឺចក្កវាឡផង ហេមវា ច គឺភ្នំហេមពាន្តផង សិនេរុ ចេវ គឺភ្នំសិនេរុផង សូរិយោ ច គឺ ព្រះអាទិត្យផង ចន្ទិមា តថា គឺព្រះចន្ទផង នក្ខត្តា ច គឺនក្ខត្តឫក្សទាំងឡាយផង ចតុរោ ទីបា ច គឺទ្វីបធំបួនផង ទ្វិសហស្សបរិត្តកា ច គឺទ្វីបតូចពីរពាន់ជាបរិវារផង ចក្កវត្តិ ច គឺស្តេចចក្រពត្តិផង សេតសង្ខោ ច គឺសង្ខសផង មច្ឆានំ យុគលំ តថា គឺត្រីគូផង ចក្កំ ច គឺចក្កផង សត្ត មហាគង្គា ច គឺស្ទឹងធំទាំងប្រាំពីរផង សត្ត មហាសេលា ច គឺភ្នំទាំងប្រាំពីរផង សត្ត មហាសរា ច គឺស្រះធំទាំងប្រាំពីរផង សុបណ្ណកោ ច គឺស្តេចគ្រុឌផង សុសុមារោ ច គឺក្រពើផង ធជោ ច គឺទង់ជ័យផង បដាកាមេវ ច គឺទង់ជ្រុងផង ចាដណ្ណី ច គឺវហ៍ផង វាលវីជនី ច គឺផ្លិតកន្ទុយចាមរីផង កេលាសបព្វតោ តថា គឺភ្នំកៃលាសផង សីហរាជា ច គឺស្តេចសីហៈ

ផង ព្យគ្ឃរាជា ច គឺស្តេចខ្លាធំផង វលាហោ ច គឺស្តេចសេះវលាហកៈផង ឧបោសថោ ច គឺដំរីឧបោសថផង វាសុកី នាគរាជា ច គឺនាគឈ្មោះវាសុកីផង ហំសោ ច គឺហង្សផង ឧសភោ តថា គឺគោឧសភផង ឯរាវណោ ច គឺដំរីឯរាវណផង មករោ ច គឺមករផង ហរិណាវា ចតុម្មុខា ច គឺសំពៅមាសមុខបួនផង សវច្ឆកា តថា គាវី គឺមេគោដោះផង កិន្នរោ ច គឺកិន្នរផង កិន្នរីបិ ច គឺកិន្នរីផង ករវីកោ ច គឺសត្វករវិកផង មយូរោ ច គឺក្ងោកផង កោញ្ចរាជា តថេវ ច គឺស្តេចក្រៀលផង ចក្កវាកទិជោ ចេវ គឺសត្វបក្សីចាក្រពាកផង ជីវញ្ជីវកនាមកោ ច គឺសត្វបក្សីព្រហីតផង ឆ កាមាវចរា ទេវា ច គឺកាមាវចរទេវលោក ៦ ជាន់ផង ព្រហ្មលោកា ច សោឡស គឺព្រហ្មលោក ១៦ ជាន់ផង ទិស្សន្តេ មាននៅប្រាកដ បាទេសុ ក្នុងព្រះបាទទាំងឡាយ យស្ស សម្មាសម្ពុទ្ធស្ស នៃព្រះសម្មាសម្ពុទ្ធអង្គណា មហេសិនោ ទ្រង់ស្វែងរកនូវគុណដ៏ធំមានសីលគុណជាដើម អហំ រីខ្ញុំព្រះអង្គ វន្ទេ សូមថ្វាយបង្គំ តំ សម្មាសម្ពុទ្ធំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះ បុរិសុត្តមំ ព្រះអង្គជាបុរសដ៏ឧត្តម ។

ស្នាមព្រះបាទជួបក្នុងគម្ពីរមហាយាន

សេចក្ដីរឿងមង្គល ១០៨ ដែលពោលមកនេះ ជាសេចក្ដីអធិប្បាយក្នុងគម្ពីរថេរវាទ ។ តែក្នុងគម្ពីរចំណែកមហាយាន ដែលតែងជាភាសាសំស្ក្រឹត មានការពោលដល់មង្គលត្រឹមពីរប្រការ មិនបានបញ្ជាក់ដល់មង្គល ១០៨ ប្រការដោយល្អិតនោះទេ ដូចគម្ពីរលលិតវិសតរៈ (អធ្យាយៈ ២៦) ពោលថា ៖

ទីឃ្យេរាត្រំ ត្យាគឝីលតបោវ្រតព្រហ្មច្រយទឫឍសមាទា-ទានចលាប្រកម្បត្វាទ្វិចិត្រស្វស្តិនន្ទ្យាវ្រគសហស្រារចក្រាង្កិត-បាទតលឥត្យប្យតេ ។

អ្នកដែលមានចក្កឈ្មោះថា អ្នកមានព្រះបាទប្រដាប់ដោយចក្កដែលមានកាំមួយពាន់ ដែលប្រកបដោយរូបសវត្ថិកៈ និងរូបផ្កាចន្ទ ព្រោះសមាទានការបរិច្ចាគ សីល ការប្រព្រឹត្តតបៈ និងព្រហ្មចរិយៈយ៉ាងមាំទាំមិនកម្រើក ។

ក្នុងគម្ពីរមហាវស្តុអវទាន មានការពោលដល់មង្គលពីរប្រការដូចពោលមកនេះ ដូចគ្នា មានសេចក្ដីថា

ហេម្ពា បាទតលា ជាតា ស្វស្តិកៃ ឧបគោភិតា
បាទង្គុលីបុ ស្រវត្រ នន្ទ្យាវត្រ ឧទ្គតា ។

ក្រោមព្រះបាទប្រាកដស្អាតដោយរូបសវត្ថិក: និងរូបផ្កាចន្ទ ប្រាកដ ហើយត្រង់ព្រះអង្គុលីទាំងអស់ ។

គោលឋានក្នុងគម្ពីរមហាយានទាំងពីរនេះបញ្ជាក់ថា ស្នាមព្រះបាទព្រះពុទ្ធ មានរូបមង្គលត្រឹមពីរប្រការប៉ុណ្ណោះ នេះជាសេចក្តីផ្ទៀងផ្ទាត់ មតិគ្នារវាងថេរវាទ និងមហាយាន ។

## អធិប្បាយសព្ទមង្គល ១០៨

សិរិវច្ឆ (រូបផ្ទះកំពូល)

ពាក្យថាសិរិវច្ឆ ក្នុងទីនេះប្រែថា ផ្ទះកំពូល សំដៅដល់ផ្ទះដែលលើកហោជាន់ដ៏ស្អាត ។ ក្នុងគិហិបដិបត្តិពិស្តារ រៀបរៀងដោយ ព្រះសីលសំវរ រស់ កែវ ប្រែថា ពពិល[១] ។

សំស្រ្កឹតប្រើជា ឝ្រីវត្ស ប្រែថា ព្រះលោមាពណ៌ស រូបកាកបាទវិលស្តាំជារង្វង់មូលរវាងកណ្តាលព្រះឱរះរបស់ព្រះវិស្ណុ ឬព្រះកប្បមណា ដូចគោលបាទក្នុងវចនានុក្រមសំស្រ្កឹតថា

ឝ្រីវត្ស.បុ.វទតិ មហត្ត្វំ វទ-ស ឝ្រិយុក្តោ វត្សះ ។ មហត្ត្វលក្សណ-គ្វេតរោមាវត្តវិឝេមេ ។ ស អស្យ្យស្យ អច វិស្ណោ[២] ។

ឝ្រីវត្ស.បុំលិង្គ.(ពាក្យថា វត្ស មានរូបវិគ្រោះថា) វទតិ មហត្ត្វំ (សម្តែងភាពជាធំ) វទ ធាតុ+ស បច្ច័យ (ពាក្យថា ឝ្រីវត្ស មានរូបវិគ្រោះថា) ឝ្រិយុក្តោ វត្សះ (ព្រះឱរះដ៏មានសិរី) រមែងប្រព្រឹត្តទៅក្នុងលក្ខណៈវិលស្តាំរបស់ព្រះលោមាពណ៌ស ដែលជាសញ្ញលក្ខណៈរបស់ភាពជាធំ (ម្យ៉ាងទៀត ពាក្យថា ឝ្រីវត្ស មានរូបវិគ្រោះថា) ស អស្យ្យស្យ

---

[១] គិហិបដិបត្តិពិស្តារ ទំព័រ ២១៤ ។ ២ សព្ទស្ត្រោមមហានិធិ ទំព័រ ៤៤២ ។

(ព្រះលោមានោះនៃព្រះវិស្ណុអង្គណាមាន) ចុះ អច បច្ច័យ រមែងប្រព្រឹត្ត ទៅក្នុងព្រះវិស្ណុ ។

តាមន័យអំពីសំស្រ្កឹតនេះ ពាក្យថា សិរិវច្ឆ មានសេចក្តីពីរប្រការ គឺ

-ព្រះឧរៈដ៏មានសិរី = សិរិយុត្តោ វច្ឆោ សិរិវច្ឆោ (មជ្ឈេលោប-សមាស)

-ព្រះវិស្ណុអ្នកមានឧរៈដ៏ទ្រង់សិរី = សិរិវច្ឆោ យស្ស អត្ថិតិ សិរិវច្ឆោ (សិរិវច្ឆ សព្ទ+ណ បច្ច័យ ក្នុងអស្សត្ថិតទ្ធិត) ។

យ៉ាងណាក៏ដោយ ក្នុងទីនេះប្រែថា ផ្ទះកំពូល តាមគោលបានក្នុងគម្ពីរដីកា ទីឃនិកាយឈ្មោះលីនត្ថប្បកាសិនីថា

សិរិវច្ឆោតិ សិរិអគារំ ។

ពាក្យថា សិរិវច្ឆោ (រូបផ្ទះកំពូល) គឺផ្ទះទ្រង់សិរី ។

ឆន្ទិយាវដ្ដ (រូបផ្កាចន្ទ) ។

ពាក្យថា ឆន្ទិយាវដ្ដ ក្នុងគិហិបដិបត្តិពិស្តារ រៀបរៀងដោយ ព្រះសីល-សំវរ រស់ កែវ ប្រែថា ផ្កាមាលតី[១] ។ ច្បាប់ខ្លះប្រែថា នន្ទិ ខ្លះ នន្ទិវត្ត ខ្លះ។ ក្នុងសំស្រ្កឹតមានរូបថា នន្ទ្យាវ្រ្តត, ប្រាក្រិតមានរូបថា ណំទិយាវត្ត និង អឌ្ឍមាគធីមានរូបថា នំទិអាវត្ត ។

---

១ គិហិបដិបត្តិពិស្តារ ទំព័រ ២១៤ ។

គោលឋានក្នុងគម្ពីរវិមតិវិនោទនីដីកាថា ៖

នន្ទិយាវដ្តន្តិ នន្ទិយាវដ្តបុប្ផាការេន មង្គលត្ថំ សុវណ្ណេន កតំ។

ពាក្យថា នន្ទិយាវដ្តំ គឺភាជនៈដែលធ្វើដោយមាស មានលក្ខណៈដូចផ្កាចន្ទ ដើម្បីភាពជាមង្គល ។

វឌ្ឍមាន (ថាសដាក់គ្រឿងសំណែន)

ពាក្យថា វឌ្ឍមាន ក្នុងគិហិបដិបត្តិពិស្តារ រៀបរៀងដោយ ព្រះសីលសំវរ រស់ កែវ ប្រែថា បាយសី[១] ។ ក្នុងទីនេះប្រែថា ថាសដាក់គ្រឿងសំណែន មានពាក្យអធិប្បាយដូចតទៅ ៖

វឌ្ឍមាន នេះប្រើជា វឌ្ឍមាន ខ្លះ វឌ្ឍមានក ខ្លះ (សំស្រ្កឹតមានរូបថា វរ្ទ្ធមាន, វរ្ទ្ធមានក ប្រាក្រិត និងអឌ្ឍមាគធីមានរូបថា វឌ្ឍមាន, វឌ្ឍមានយ) ។

វរ្ទ្ធមាន.បុ.វឫធ-គានច.ឯរណ្ឌវឫក្សៈ, វឫទ្ធិគីលេ ត្រិ.គភរេ (មឫត្យាត្រកេទ) វិប្ណោ, ធនិនាំ គឫហភេទ, នគរភេទ ច ។ វឫទ្ធិយក្តេត្រិ[២] ។

វរ្ទ្ធមាន.បុំលិង្គ.សម្រេចរូបមកពី វឫធ-គានច បច្ច័យ ប្រើក្នុងសេចក្តីថា ដើមល្ហុង, ជាត្រៃលិង្គប្រើក្នុងសេចក្តីថា អ្នកចម្រើនដោយប្រក្រតី និងប្រើក្នុងសេចក្តីថា ថាស (ដាក់គ្រឿងសំណែន), ថាសផឹកទឹក

---

[១] គិហិបដិបត្តិពិស្តារ ទំព័រ ២១៤ ។ ២ សព្ទស្តោមមហានិធិ ទំព័រ ៣៨២ ។

អម្រឹត, ព្រះវិស្ណុ, គប្ងហាសថរបស់អ្នកមានទ្រព្យ, ស្ថានទីចំពោះ (ដែលឈ្មោះថា វទ្ធមាន) និងនគរចំពោះ (ដែលឈ្មោះថា វទ្ធមាន) ។

រូបមង្គលដូចពោលមកនេះ ត្រូវត្រង់សិល្បៈឥណ្ឌាសម័យបុរាណ ដែលធ្វើជារូបថាសដាក់គ្រឿងសំណែនតាំងទុកបូជាមុខទេវរូប ដែលគួរគោរព ។ ក្នុងវត្តហិណ្ឌូខ្លះ នៅរក្សាវត្ថុនេះទុកជាវត្ថុបុរាណរបស់វត្ត ។

សេចក្តីនេះនៅប្រាកដក្នុងគម្ពីរអភិធានប្បទីបិកាដីកា (ពាក្យអធិប្បាយគាថា៤៥៨) ថា វឌ្ឍមានកោបត្រ (សូម្បី វឌ្ឍមានកោ ក៏មានក្នុងសេចក្តីថា ថាស នេះ ។

សោវត្ថិកៈ (រូបសវត្ថិកៈ)

សោវត្ថិកៈ ក្នុងគិហិបដិបត្តិពិស្តារ រៀបរៀងដោយ ព្រះសីលសំវរ ស់ កែវ ប្រែថា សង្វារខ្វែងឬសង្វារគោប[1] ។ ពាក្យនេះគួរប្រែថា រូបសវត្ថិកៈ គឺស្នាមកាកបាទចុងបាក់មុមស្តាំ សំដៅដល់ ការវិលរបស់កាលវេលាភាពមាំទាំ ។ សន្និដ្ឋានថា រូបព្រះអាទិត្យគោចរវិលទៅស្តាំ (សំស្រ្កឹតថា ស្វស្តិក ប្រាក្រិតមានរូបថា សោវត្ថិអ អឌ្ឍមាគធីមានរូបថា សោវត្ថិយ) ពាក្យនេះប្រកបរូបសព្ទមកពី សុវត្ថិ សព្ទ+ណិក បច្ច័យ ក្នុងអវហតិតទ្ធិត មានរូបវិគ្រោះក្នុងដីកា មជ្ឈិមនិកាយថា

សុវត្ថិ អនុបទ្ធំ អាវហាតីតិ សោវត្ថិកោ ។

---

[1] គិហិបដិបត្តិពិស្តារ ទំព័រ ២១៤ ។

*សោវត្ថិក: គឺវត្ថុដែលនាំមកនូវសួស្តី ពោលគឺប្រាសចាកឧបសគ្គ។*

*ម្យ៉ាងទៀត សម្រេចរូបមកពី សោត្ថិ សទ្ទ+ ឋន បច្ច័យ ក្នុង ហិត តទ្ធិត មានរូបវិគ្រោះពោលទុកក្នុងគម្ពីរសទ្ទសោ្តមមហានិធិ (ទំព័រ ៥០៤) ថា សោត្ថិនោ សុភាយ ហិតំ សោវត្ថិកំ (សោវត្ថិក: គឺវត្ថុដែលនាំផ្តល់ផ្តើមដល់សួស្តី ពោលគឺសេចក្តីល្អ) ។*

វដំសក (ផ្កាឈើក្រងលើសីស:)

*វដំសក នេះជួបក្នុងអភិធានប្បទីបិកាថា ឧត្តំសោ សេខរាវេឡា មុទ្ធមាល្យំ វដំសកោ (ឧត្តំស,សេខរ,អាវេឡ,មុទ្ធមាល្យ, និងវដំសក= ផ្កាឈើក្រងលើសីស:) ។ សូម្បីក្នុងមជ្ឈិមដីកាព្រះសូត្រក៏អធិប្បាយថា*

វដំសកោតិ អាវេឡំ។

*ពាក្យថា វដំសកោ ប្រែថា ផ្កាឈើក្រងលើសីស: ។*

**ពុទ្ធគុណ**

ឯវំ អចិន្តិយា ពុទ្ធា ពុទ្ធធម្មា អចិន្តិយា

អចិន្តិយេ បសន្នានំ វិបាកោ ហោតិ អចិន្តិយោ។

*ព្រះពុទ្ធទាំងឡាយ ជាអចិន្តិយបុគ្គល (បុគ្គលដែលគេមិនគប្បីគិតកើត) ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌ យ៉ាងនេះ កាលបុគ្គលជ្រះថ្លា ចំពោះគុណជាអចិន្តិយ: រមែងបានផលជាអចិន្តិយ: ។*

*(ខុទ្ទក.៧២/១៥)*

ការទទួលយកទៅបោះពុម្ពផ្សាយជាធម្មទាន

ក្រោមការឧបត្ថម្ភបោះពុម្ពរបស់មូលនិធិពុទ្ធិកសិក្សានៅតៃវ៉ាន់

(The Corporate Body of the Buddha Educational Foundation) ។

ដោយអាស្រ័យលើការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម៖

- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានប្រទះឃើញនូវសៀវភៅនេះមានដាក់លក់នៅកន្លែងណា ឬចង់បានសៀវភៅធម៌យកទៅអាន

សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទៈ (៨៥៥) ១២ ៩៦១ ៤២៩, (៨៥៥) ៨៨៧ ៩៦១ ៤២៩

អ៊ីមែលៈ maha.panna@gmail.com

គេហទំព័រៈ http://www.mahapanna.org

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.

May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**

**南無阿彌陀佛**

《柬埔寨文：A short History of the Buddha's Relics,
佛陀遺跡的小故事》

財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org

**This book is strictly for free distribution, it is not to be sold.**

សម្រាប់ចែកជាធម្មទាន

Printed in Taiwan
3,000 copies; September 2015
CA057 - 13496